# សៀវភៅ

## ស្តីពី

# ថ្នាលបណ្តុះកូនឈើ និង ដំណាំឈើហូបផ្លែ




<u>រៀបចំដោយៈ</u> លោក សួ ហៃ មន្ត្រីសមភាគីផ្នែកកសិរុក្ខកម្ម នៃ FAO ខេត្តសៀមរាប

លោក ចៅ ជាង មន្ត្រីសមភាគីផ្នែកកសិរុក្ខកម្ម ផ្នែកបណ្តុះបណ្តាល ផ្សព្វផ្សាយ និងការងារទំនាក់ទំនង(TEC) នៃ FAO ខេត្តសៀមរាប



<u>ឧបត្ថម្ភដោយៈ</u> អង្គការ FAO ខេត្តសៀមរាប

សៀមរាប ថ្ងៃទី ២៣ មេសា ឆ្នាំ ២០០៤

## បញ្ជីឈ្មោះសមាជិកក្រុមផ្នែកកសិរុក្ខកម្ម
## អង្គការ FAO ខេត្តសៀមរាប
## 222222

១- លោក សួ ហៃ ប្រធានផ្នែករដ្ឋបាលព្រៃឈើជីក្រែង និង ជាមន្ត្រីសមភាគីផ្នែកកសិរុក្ខកម្ម នៃអង្គការ **FAO** ខេត្តសៀមរាប

២- លោក ប៉ៅ ជាង មន្ត្រីការិយាល័យផ្សព្វផ្សាយកសិកម្ម និង ជាមន្ត្រីសមភាគីផ្នែកកសិរុក្ខកម្ម ផ្នែក **TEC** នៃ **FAO** ខេត្តសៀមរាប

៣- លោក ឡាយ សុផល មន្ត្រីផ្នែករដ្ឋបាលព្រៃឈើ និងជាមន្ត្រីសមភាគីផ្នែកកសិរុក្ខកម្ម នៃអង្គការ **FAO** ខេត្តសៀមរាប

៤- លោក វ៉ាន់ ហឿង ភ្នាក់ងារផ្សព្វផ្សាយដំណាំឈើហូបផ្លែ

# បញ្ជីអត្ថបទ


ទំព័រ

I- ការធ្វើផែនការថ្នាល ............................................................ ១

១- ផែនការសំរាប់អនុវត្ត ............................................................ ១

២- កម្មវិធីនៃការផលិត ............................................................ ២

៣- ការកត់ត្រា ............................................................ ២

៤- តំលៃនៃកូនឈើ ............................................................ ២

II- ការបង្កើតថ្នាល ............................................................ ៤

១- ការជ្រើសរើសទីតាំង ............................................................ ៤

២- ការធ្វើផែនទីពង្រាង ............................................................ ៥

៣- ការសាងសង់ថ្នាល ............................................................ ៥

៣-១-រងដាក់ថង ............................................................ ៥

៣-២-រងផ្សាំ ............................................................ ៥

៣-៣-រង ឬថាសសាប ............................................................ ៦

៤- ការរៀបចំប្រពន្ធ័ទឹក ............................................................ ៦

III- ការរៀបចំដី និងការលាយដីសំរាប់ច្រកថង់ ............................................................ ៦

IV- ការប្រមូលគ្រាប់ពូជ............................................................ ៩

V- បច្ចេកទេសបណ្តុះកូនឈើដោយគ្រាប់............................................................ ១០

VI-ការស្ទូងកូនឈើក្នុងថង់............................................................ ១៤

VII-បច្ចេកទេសបណ្តុះកូនឈើតាមសរីរាង្គ............................................................ ១៧

១-អត្ថប្រយោជន៏............................................................ ១៧

២-វិធីសាស្ត្រនៃការបណ្តុះកូនឈើតាមសរីរាង្គ............................................................ ១៧

២-១-ការបណ្តុះកូនឈើដោយមែក ............................................................ ១៧

២-២-ការបណ្តុះកូនឈើដោយគល់ ឬស្ទុំ ............................................................ ១៨

២-៣-ការដាំឈើដោយផ្សាំ ............................................................ ១៩

VIII-ការថែទាំកូនឈើ ............................................................ ២០

IX- ការដាំឈើ........................................................................................ ២៦
១-ការងារដែលត្រូវរៀបចំមុនពេលដឹកកូនឈើទៅដាំ ............................................ ២៦
ក-ចំពោះកូនឈើបណ្តុះក្នុងថង់ ........................................................ ២៦
ខ-ចំពោះកូនឈើបណ្តុះក្នុងរងផ្សាំ ...................................................... ២៧
២-ការរៀបចំដី ............................................................................. ២៧
៣-គំលាតដាំ ............................................................................... ២៧
៤-ការជីករណ្តៅ ............................................................................ ២៨
៥-ការដាំ ................................................................................... ២៨
៦-ការថែរក្សា ............................................................................... ៣០
X- អំពីជី ........................................................................................ ៣១
១-ជីអសរីរាង្គ ............................................................................... ៣១
២-ជីសរីរាង្គ ................................................................................. ៣១
XI- ការធ្វើជីកំប៉ុស្ត................................................................................ ៣២
១-តើកំប៉ុស្តជាអ្វីទៅ ......................................................................... ៣២
២-តើអ្វីបានកើតឡើងនៅពេលធ្វើកំប៉ុស្ត ..................................................... ៣២
៣-តើកំប៉ុស្តមានសារធាតុចិញ្ចឹមអ្វីខ្លះសំរាប់ដំណាំ ............................................ ៣៣
៤-ផលប្រយោជន៏នៃកំប៉ុស្ត ................................................................. ៣៤
៥-សំភារះសំរាប់ធើជីកំប៉ុស្ត ................................................................. ៣៥
៥-១-សំភារះប្រើប្រាស់ ....................................................................... ៣៥
៥-២-សារធាតុសរីរាង្គ ....................................................................... ៣៥
៦-ការរៀបចំធ្វើជីកំប៉ុស្ត ..................................................................... ៣៦
៦-១-របៀបធ្វើជីកំប៉ុស្តលើដីរាបស្មើ ........................................................ ៣៦
៦-២-របៀបធ្វើជីកំប៉ុស្តក្នុងទ្រុង ............................................................ ៤០
XII- ដំណាំឈើហូបផ្លែ ......................................................................... ៤៣
១- ផលប្រយោជន៏នៃដំណាំឈើហូបផ្លែ.......................................................... ៤៣
២- រដូវនៃការដាំដុះ .......................................................................... ៤៣

៣- ការជ្រើសរើសទីកន្លែងដាំ ............................................................ ៤៣
៤- ការរៀបចំដីសំរាប់ធ្វើចំការ ............................................................ ៤៣
៤-១-ការរៀបចំប្លង់ ............................................................ ៤៣
៤-២-ការរៀបចំរបងការពារ ............................................................ ៤៤
៤-៣-ការរៀបចំប្រព័ន្ធស្រោចស្រព ............................................................ ៤៤
៤-៤-ការរៀបចំប្រព័ន្ធដាំដុះ ............................................................ ៤៤
ក-ការរៀបចំរង ............................................................ ៤៤
ខ-គំលាតដាំ ............................................................ ៤៤
គ-ការរៀបចំរណ្ដៅ ............................................................ ៤៤
៥-ការជ្រើសរើសពូជ ............................................................ ៤៥
៦-របៀបដាំ ............................................................ ៤៥
៧-ការគ្រប់គ្រងចំការ ............................................................ ៤៦
ក- ការស្រោចស្រព ............................................................ ៤៦
ខ- ការកំចាត់ស្មៅ ............................................................ ៤៦
គ- ការដាក់ជី ............................................................ ៤៦
ឃ- ការតាក់តែងមែក ............................................................ ៤៨
៨-ការពង្រីកពូជ ............................................................ ៤៨
ក- របៀបសាក ............................................................ ៤៨
ខ- របៀបបំបៅ ............................................................ ៤៩
គ- របៀបតត្រួយ ............................................................ ៥០
ឃ- របៀបពុះបញ្ចូលត្រួយ ............................................................ ៥០
ង- របៀភ្ជាប់ភ្នែក ............................................................ ៥១
XIII- វិធីសាស្ត្រក្នុងការកំចាត់កត្តាចង្រៃលើដំណាំ............................................................ ៥២
១-ការកំចាត់ដោយប្រើអន្ទាក់ភ្លើង............................................................ ៥២
២-ការកំចាត់ដោយចាប់និងដៃ ............................................................ ៥២
៣-ការកំចាត់តាមរបៀបដាំដុះ ............................................................ ៥២

៤-ការកំចាត់តាមរបៀបជីវសាស្ត្រ..................................................................... ៥២

៥-ការកំចាត់ដោយប្រើថ្នាំពុល ..................................................................... ៥២

៥-១-ថ្នាំពុលផ្សំពីរុក្ខជាតិ ............................................................... ៥២

៥-២-ថ្នាំពុលកសិកម្ម .................................................................. ៥៨

៥-២-១-និយមន័យ ............................................................... ៥៨

៥-២-២-ក្រុមថ្នាំពុលកសិកម្ម ..................................................... ៥៨

៥-២-៣-បែបផែនសកម្មភាពរបស់ថ្នាំពុលកសិកម្ម ............................. ៥៨

៥-២-៤-ការជ្រើសរើសថ្នាំពុលកសិកម្ម ......................................... ៥៩

៥-២-៥-គ្រោះថ្នាក់ ............................................................... ៥៩

ក-គ្រោះថ្នាក់ពុលដល់មនុស្ស និងសត្វ ............................... ៥៩

ខ-ធ្វើអោយក្រខ្វក់ដល់បរិស្ថាន ......................................... ៥៩

គ-ការពុលដល់រុក្ខជាតិ ................................................. ៦០

៥-២-៦-ការកាន់កាប់ និងការប្រើប្រាស់ថ្នាំពុលអោយមានសុវត្ថិភាព......... ៦០

៥-២-៧-ចំណាត់ថ្នាក់ថ្នាំពុល .................................................. ៦១

៥-២-៨-រោគសញ្ញានៃការពុលថ្នាំ ............................................ ៦២

៥-២-៩-ការសង្គ្រោះបន្ទាន់ .................................................... ៦២

៥-២-១០-ការថែរក្សាបរិស្ថាន ................................................ ៦២

៥-២-១១-វិធានការណ៍ការពារ និងកំចាត់កត្តាចង្រៃ......................... ៦៧

សៀវភៅដែលបានដកស្រង់ ......................................................................

# ការបណ្តុះកូនឈើ

## I. ការធ្វើផែនការថ្នាល

### គោលបំណង:

◊ ដើម្បីពង្រឹងជំនាញផ្នែកផែនការរបស់អ្នកចូលរួមសំរាប់ការបង្កើត និងការគ្រប់គ្រង ថ្នាលដោយមានការ គូសបញ្ជាក់នូវការជ្រើសរើសទីតាំងអោយបានសមស្រប ។ ការ ងារថ្នាលបណ្តុះកូនឈើដែលទទួលបានជោគជ័យនោះតំរូវអោយមានការធ្វើផែនការ អោយបានត្រឹមត្រូវ ដែលក្នុងនោះមានគោលបំណងច្បាស់លាស់មួយត្រូវបានធ្វើឡើង ដូចជា :

- ➢ តម្រូវការអំពីប្រភេទឈើ
- ➢ ចំនួនកូនឈើដែលត្រូវបណ្តុះឬ ត្រូវផលិតក្នុងមួយឆ្នាំ ។
- ➢ ប្រភេទនៃកូនឈើ (បណ្តុះដោយគ្រាប់ ឬដោយសរីរាង្គ ឬស្ទូម)
- ➢ ទីតាំងដែលកូនឈើត្រូវបានយកទៅដាំ
- ➢ រំពឹងគិតថា តើថ្នាលប្រើប្រាស់សំរាប់បណ្តុះកូនឈើប៉ុន្មានឆ្នាំ
- ➢ វិធីសាស្ត្រក្នុងការផលិត និងពេលវេលានៃការផលិត ។

ជារួមថ្នាលបណ្តុះកូនឈើត្រូវធ្វើយ៉ាងណាបណ្តុះកូនឈើអោយមានគុណភាពល្អ តាមប្រភេទកូនឈើដែលត្រូវការ អោយទាន់ពេលវាលា និង ទំហំកូនឈើដែលត្រូវដាំ ក្នុងចំនួនគ្រាប់គ្រាន់ និងតំលៃសមរម្យ ។ ជាមួយនេះដែរ ថវិកាគួរយកចិត្តទុកដាក់ បំផុតសំរាប់ចំណាយទៅលើកំលាំងពលកម្ម និងសំភារៈផ្សេងៗក្នុងការដំណើរការថ្នាល។

### ការធ្វើផែនការរួមមាន:

#### ១. ផែនការអនុវត្ត

◊ ហេដ្ឋារចនាសម្ពន្ធ័(ទឹកស្រោចស្រព្វ របងការពារ រោងកម្មករ ឬកន្លែងទុកដាក់ សំភារៈ ។ល។)

◊ សំភារៈសាងសង់ថ្នាល (បង្គោល ស្បៃគ្រប ក្រាក់របង...។ល។)

◊ ឧបករណ៍ (ចប បង្គី ប៉ែល កញ្ច្រែងរែងដី ...។ល។)

◊ សំភារៈបំរើថ្នាល ( ថង់ ដី ជីរ ដីខ្សាច់....។ល។)

◊ ការផ្តល់គ្រាប់ពូជ (ប្រមូលខ្លួនឯង ទិញពីប្រជាជន ចំនួនប៉ុន្មាន ប្រភេទអ្វីខ្លះ?)

◊ កំលាំងពលកម្ម (កម្មករអចិន្ត្រៃយ៍ បណ្តោះអាសន្ន អ្នកមើលការខុសត្រូវដែល បានបណ្តុះបណ្តាល...។ល។)

## ២. កម្មវិធីនៃការផលិត

◊ ថ្នាលបណ្តុះកូនឈើនីមួយៗត្រូវមានកម្មវិធីបណ្តុះមួយច្បាស់លាស់ដោយផ្អែកទៅលើ គោលដៅ ឬចំនួនផលិត (តើផលិតប្រភេទឈើអ្វី? មានចំនួនប៉ុន្មាន? របៀបណានៅពេលណា?) និងអាស្រ័យទៅតាមអត្រាលូតលាស់នៃប្រភេទនីមួយៗ ដោយគិត ចាប់ពីថ្ងៃបណ្តុះរហូតទៅដល់ ទំហំដើមដែលអាចដាំបាន ។

## ៣. ការកត់ត្រា

ដើម្បីកែលំអរក្នុងការធ្វើផែនការ និង ការបណ្តុះកូនឈើទៅអនាគត ការកត់ត្រានៃការងារថ្នាលត្រូវតែធ្វើអោយបានល្អដែលក្នុងនោះ យើងគួរកត់ត្រាទៅលើ :

- ឈ្មោះប្រភេទកូនឈើ ទីតាំងប្រមូលគ្រាប់ ថ្ងៃខែប្រមូល ឈ្មោះអ្នកប្រមូលគ្រាប់ របៀបប្រព្រឹត្តកម្ម និង ថ្ងៃ ខែសាបគ្រាប់
- ថ្ងៃ ខែ ដែលកូនឈើអាចដកស្ទូងបាន និង ពេលវេលាដែលត្រូវស្ទូងកូន
- កត់ត្រាសកម្មភាពថ្នាលប្រចាំថ្ងៃ
- ធ្វើសារពើភ័ណ្ឌនៃការផ្គត់ផ្គង់ ដូចជាគ្រាប់ពូជ ថង់ ឧបករណ៍ ។ល។
- កត់ត្រានូវកម្មករដែលមកធ្វើការ និង ការចំណាយ
- កត់ត្រាការបញ្ចេញកូនឈើយកទៅដាំ (ប្រភេទឈើ ចំនួន ឈ្មោះអ្នកយក កូនឈើ ទីតាំងដាំជាដើម ...។ល។)

## ៤. តំលៃនៃកូនឈើ

◊ ប៉ាន់ស្មាន និង កំនត់តំលៃកូនឈើ (ថ្នាំ ជីគីមី គ្រាប់ពូជ ថង់ ដី ជីកំប៉ុស្តិ៍ ឬលាមកសត្វ កំលាំងពលកម្ម...។ល។)

# ប្រតិទិន ថ្នាលបណ្តុះកូនឈើ

| សកម្មភាពការងារ | ខែ | | ខែនៃឆ្នាំ | | | | | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | ១០ | |
| 1,**<u>ធ្វើផែនការថ្នាល</u>**(ផែនការអនុវត្ត,ពេលវេលានៃការផលិត,ការកត់ត្រា តំលៃនៃកូនឈើ ) | | ▬ | ▬ | | | | | | | | | | |
| 2,**<u>ការបង្កើតថ្នាល</u>** | | | | | | | | | | | | | |
| -ជ្រើសរើសទីកន្លែង | ▬ | ▬ | | | | | | | | | | | |
| -ធ្វើពង្រាងផែនទី | ▬ | ▬ | | | | | | | | | | | |
| -សាងសង់ថ្នាល(សំអាតទីធ្លា,ភ្ជួរដី ធ្វើរបង,ធ្វើរងសំរាប់ធ្វើរនិងដាក់សំភារៈ,ផ្លូវដើរ,រងផ្សាំ រងសាបនិង គំបម្លប់ ) | | ▬ | ▬ | ▬ | | | | | | | | | |
| -រៀបចំប្រព័ន្ធទឹក | | | | ▬ | | | | | | | | | |
| 3,**<u>ការលាយដី</u>** | | | | | | | | | | | | | |
| -ប្រមូលដី | | ▬ | ▬ | | | | | | | | | | |
| -ដីខ្សាច់និងលាមកសត្វ | | | ▬ | ▬ | | | | | | | | | |
| -រែងដីនិងលាយដី | | | | ▬ | ▬ | | | | | | | | |
| -ច្រកដីដាក់ថង់ | | | | ▬ | ▬ | ▬ | | | | | | | |
| 4,**<u>ប្រមូលគ្រាប់ពូជ</u>** | | | | | | | | | | | | | |
| -ជ្រើសរើសឈើមេពូជ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | | | | | | | |
| -ប្រមូលគ្រាប់ពូជ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | | | | | | ▬ | |
| -ថែរក្សាគ្រាប់ពូជ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | | | | | | ▬ | |
| -ធ្វើតិះគ្រាប់ពូជ | | | ▬ | ▬ | ▬ | ▬ | | | | | | | |
| 5,**<u>សាបគ្រាប់ពូជ</u>** | | | | | | | | | | | | | |
| -ធ្វើរងសាប ឬរងផ្សាំ | | | ▬ | ▬ | | ▬ | | | | | | | |
| -រៀបរងដាក់ថង់ | | | | ▬ | ▬ | ▬ | | | | | | | |
| 6,**<u>ស្ទូងកូនក្នុងថង់</u>** | | | | | | | | | | | | | |
| -ដកនិងស្ទូងកូនឈើ | | | | | ▬ | ▬ | ▬ | | | | | | |
| -ថែរក្សាកូនសំណាប | | | ▬ | ▬ | ▬ | ▬ | ▬ | ▬ | | | | | |
| 7,**<u>ការថែទាំកូនឈើ</u>** | | | | | | | | | | | | | |
| -ស្រោចទឹកនិងសំអាតស្មៅ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | ▬ | |
| -ការកាត់ឫសឬប្តូរទីតាំងកូនឈើ | | | | | | | ▬ | ▬ | | | | | |
| -ធ្វើអោយរឿលនៃកូនឈើ | | | | | ▬ | ▬ | ▬ | | | | | | |

# II. ការបង្កើតថ្នាល

## គោលបំណង:

ដើម្បីពង្រឹងជំនាញរបស់អ្នកចូលរួមនៅក្នុងការបង្កើតថ្នាល គំនូសព្រាង និងការសាងសង់ថ្នាល ។



**ការបង្កើតថ្នាលបណ្តុះកូនឈើ**

## ១. ការជ្រើសរើសទីតាំង

ដីរាបស្មើមិនលិចទឹក មានផ្លូវចេញចូលស្រួល កន្លែងស្រលះល្អ មានកំលាំង ពលកម្មនៅក្បែរមានប្រភពទឹកគ្រប់គ្រាន់ ជិតតំបន់ដាំឈើ និងនៅជិតប្រភពដី ដី ដីខ្សាច់ ដែលអាចប្រមូលច្រកថង់បាន ។

- ថ្នាលបណ្តុះកូនឈើបណ្តោះអាសន្ន
  - ◊ គំរោងដាំដុះរយៈពេលខ្លី ផ្ទៃដីដាំដុះមានទំហំតូច
  - ◊ ចំណាយទុនទាប ប្រើប្រាស់សំភារៈថោក
- ថ្នាលបណ្តុះកូនឈើអចិន្ត្រៃយ៍
  - ◊ សំរាប់ផ្គត់ផ្គង់កូនឈើរយៈពេលវែងនិងខ្លី
  - ◊ មានគ្រប់រចនាសម្ព័ន្ធរបស់ថ្នាលធានាការប្រើប្រាស់រយៈពេលវែង ( រោងកម្មករ រោងជីកំប៉ុស្ត ប្រពន្ធ័ទឹក....។ល។)
  - ◊ សំភារៈប្រើប្រាស់ប្រកបដោយគុណភាព

## ២. ការធ្វើផែនទីពន្យល់ខាង

- ◊ ផ្លូវគមនាគមន៍ / ផ្លូវលំ
- ◊ ទីធ្លាសំរាប់ធ្វើការ / កន្លែងទុកដី ជី...
- ◊ រង (រងសាប រងសំរាប់ដាក់ថង់ រងផ្សាំ)
- ◊ ផ្លូវដើរ
- ◊ រោងទុកសំភារៈ
- ◊ រោង / ផ្ទះកម្មករ / បង្គន់អនាម័យ
- ◊ រណ្តៅដីកំប៉ុស្ត

## ៣. ការសាងសង់ថ្នាល

- ◊ សំអាតទីធ្លា ភ្ជួរដី ធ្វើរបង រោងសំរាប់ធ្វើការ ផ្លូវដើរ ធ្វើរងសាប រងផ្សាំ រងដាក់ថង់ ធ្វើក្រសាល ឬគំរបម្លប់

### ៣.១ រងដាក់ថង់

រងដាក់ថង់ធ្វើឡើងសំរាប់ការបណ្តុះកូនឈើដោយតាមរយៈថង់ ។ រងដាក់ថង់ ត្រូវបានធ្វើឡើងតាមវិធីសាមញ្ញ ដូចតទៅ :

- ➢ ពង្រាបដីអោយបានស្មើ និងធ្វើទំរព័ទ្ធជុំវិញអោយបានកំពស់ពីដី ពី១០-១៥ស.ម ដើម្បីទប់ថង់កូនឈើកុំអោយដួល
- ➢ សំភារៈសំរាប់ធ្វើទំរទប់អាចធ្វើពីបន្ទះឈើ ឬស្សី ឬ ឥដ្ឋ
- ➢ នៅបាតរងគួរក្រាលសំពត់កៅស៊ូ ដើម្បីការពារកុំអោយប្រពន្ធ័ឫសចាក់ចេញពីថង់ចូលទៅក្នុងដី សំពត់កៅស៊ូត្រូវក្រាលអោយបានរាបស្មើជៀសវាងកុំអោយមានដក់ ទឹក

### ៣.២. រងផ្សាំ

រងផ្សាំធ្វើឡើងសំរាប់ការបណ្តុះកូនឈើ "bare-root seedlings " និង Stumps "root-shoot cuttings" ។ រងផ្សាំអាច អាចធ្វើបានតាមវិធី ដូចតទៅ :

- ➢ សំអាតទីកន្លែងធ្វើ ហើយកាប់យកដីស្រទាប់លើចេញ ទុកមួយផ្នែកសិន
- ➢ កាប់ជ្រួយដីស្រទាប់ទីពីរ អោយបានជំរៅពី ២០-៤០ សម
- ➢ កាប់ប្រមូលដីនៅសងខាង ពូនលើរងអោយបានកំពស់ ១៥ សម
- ➢ យកដីស្រទាប់លើមកលាយជាមួយជីកំប៉ុស្តដាក់បន្ថែមទៅលើរងក្នុងករណី មានជីកំប៉ុស្ត

➢ ជាចុងក្រោយយកដីល្បាយ (ដីព្រៃ ដី ដីខ្សាច់ ) មកដាក់បន្ថែមលើរង ហើយពង្រាបអោយស្មើដោយប្រែប្រាស់រនាស់

### ៣.៣ រងប្តូថាសាប

រងសាបធ្វើឡើងសំរាប់បណ្តុះគ្រាប់ដែលតូចៗ ដូចជា ប្រេងខ្យល់ អាកាស្យា ជាដើម ។ ការរៀបចំរងនេះធ្វើដូចរងផ្សាំដែរ តែមិនប្រើដីកំប៉ុស្តបន្ថែមទេ ព្រោះអាចមានបញ្ហាដូចជា ពពួកផ្សិតកើតឡើងចំពោះគ្រាប់តូចៗ ។

### ៤. ប្រព័ន្ធទឹក

◊ ថ្នាលបណ្តោះអាសន្ន: ប្រើធុងសាំងចំណុះ២០០លីត្រ ដាក់ចន្លោះរងកូនឈើសំរាប់ដងស្រោច

◊ ថ្នាលអចិន្ត្រៃយ៍: ធ្វើអាងសំរាប់ស្តុកទឹក សង់ឱ្យខ្ពស់ និងធ្វើប្រព័ន្ធបង្ហូរស្រោចស្រពរងកូនឈើ

## III. ការរៀបចំដី និងការលាយដីសំរាប់ច្រកថង់

### គោលបំណង:

ផ្តល់នូវព័ត៌មានជាក់ស្តែងដល់អ្នកចូលរួមអំពីគុណភាពដី ការលាយដីសំរាប់ការងារថ្នាល ហើយនឹងធ្វើអោយពួកគេអាចរក្សាដីជាតិដីអោយបានល្អប្រសើរនៅក្នុងថ្នាលរបស់ពួកគេ ។




**សកម្មភាពលាយដីសំរាប់ច្រកដាក់ថង់**

◊ ការប្រព្រឹត្តកម្មដី(ការប្រព្រឹត្តកម្មដីដោយដុតកំដៅ ប្រព្រឹត្តកម្មដោយកំដៅព្រះអាទិត្យ ប្រព្រឹត្តតាមបែបគីមី និង ស្រោចទឹកក្តៅ )

◊ ប្រភេទដីៈ ដីព្រៃ (...) ឬដីដំបូក ដីខ្សាច់ លាមកសត្វ ឬដីកំប៉ុស្ត

◊ បន្ទាប់ពីលាយហើយត្រូវគ្របទុកដាក់កុំអោយត្រូវទឹកភ្លៀង ។



**សកម្មភាពរែងដី**

◊ ការរែងដីៈ បន្ទាប់ពីបំបែកដីហើយ ត្រូវរែងនឹងសំណាញ់ដែលមានក្រឡា ១០mm x ១០mm យកដីដុំចេញ និងសំរាម

◊ ការលាយដីៈ ដីព្រៃឬដីដំបូក ៣ភាគ ដីខ្សាច់១ភាគ លាមកសត្វឬដីកំប៉ុស្ត ១ភាគ



**សកម្មភាពច្រកដីដាក់ថង់**

◊ ត្រូវជ្រើសរើសថង់ឱ្យបានសមស្របតាមប្រភេទកូនឈើនិងរយៈពេលទុកវាក្នុងថ្នាល

◊ ការច្រកដីចូលថង់ៈ ត្រូវប្រើប្រដាប់ច្រក ដូចជាកំប៉ុងពុះជាចំណិត ហើយច្រកអោយពេញ និងណែនល្មម

## ការអនុវត្តន៍

-ប្រើម្រាមដៃដើម្បីបើកមាត់ថង់

-កាន់ថង់ក្នុងស្ថានភាពបើកមាត់ដោយប្រើម្រាមដៃនិងចង្អុលដៃ

-ប្រើដៃផ្សេងទៀតដើម្បីច្រកល្បាយដីចូលក្នុងថង់ និង អង្រួនថង់តិចៗ

-តំរៀបថង់ក្នុងរង: បន្ទាប់ពីច្រកហើយ ត្រូវដឹកដោយរទេះរុញ ឬ យួរដោយឡាំង ឈើ ឬបង្គី ទៅតំរៀបក្នុងរងអោយបានបញ្ឈរត្រង់ និង ជាជួរអោយបានល្អដើម្បីអោយកូនឈើងាយលូតលាស់ និងងាយស្រួលក្នុងការរាប់ចំនួន ។

-ស្រោចទឹកចូលក្នុងថង់មួយថ្ងៃមុនសួងឬដាំ ប្រសិនបើថង់ខ្វះដី ត្រូវដាក់ដីបន្ថែមពីលើ



**សកម្មភាពតំរៀបថង់ក្នុងរង**

## IV. ការប្រមូលគ្រាប់ពូជ

## ត្រូវការគ្រាប់ពូជល្អៈដើមឈើមេល្អៈកូនឈើល្អ

### គោលបំណងៈ

ផ្តល់សមត្ថភាពដល់អ្នកចូលរួមនូវពត៌មានជាក់ស្តែង សំរាប់ការធ្វើផែនការ និង អនុវត្តកម្មវិធីប្រមូលគ្រាប់ពូជអោយមានប្រសិទ្ធិភាព ដើម្បីបំពេញតម្រូវការគ្រាប់ពូជប្រចាំឆ្នាំ។

❋ ការធ្វើផែនការប្រមូលគ្រាប់ពូជ

-ប្រភេទឈើដែលត្រូវប្រមូល (ប្រភេទឈើអ្វីខ្លះ?)

-ចំនួនគ្រាប់ពូជ ( ប៉ុន្មានគីឡូក្រាម?)

-ប្រភពគ្រាប់ពូជ ( ប្រមូលគ្រាប់ពីកន្លែងណា?)

-ពេលវេលាដែលត្រូវប្រមូលគ្រាប់ពូជ ( តើត្រូវប្រមូលនៅពេលណា?)

-វិធីសាស្ត្រនៃការប្រមូល ( តើប្រមូលដោយរបៀបណា?)

❋ ការជ្រើសរើសឈើមេពូជ

-ឈើដែលមានសុខភាពល្អ គ្មានជំងឺ និងគ្មានសត្វល្អិតបំផ្លាញ

-ឈើពេញវ័យ ហើយដើមឈរត្រង់ល្អ

-ឈើដែលកំពុងលូតលាស់ក្នុងចំណោមឈើដែលមានសុខភាពល្អ និងប្រភេទឈើដូចគ្នា

-កត់ត្រានិងធ្វើកំណត់សំគាល់នៅលើផែនទី

❋ មិនត្រូវប្រមូលគ្រាប់ពូជមកពី

.ដើមឈើដែលដុះតែឯង (ឯកកោ)

.ដើមឈើដែលអោយផ្លែផ្កាឆាប់បំផុត

.ដើមឈើដែលមើលទៅមិនមានសុខភាពល្អ

❋ ជៀសវាងការប្រមូលគ្រាប់ពូជពី

.ដើមឈើដែលដុះមានចំនួនតិច

.ដើមឈើដែលមានលក្ខណៈផេណូទីបមិនល្អក្នុងប្រភេទឈើដូចគ្នា

.ដើមឈើក្នុងព្រៃរិចរិល

.ដើមឈើដែលមានទិន្នផលគ្រាប់តិច

.ដើមឈើដែលមានអាយុនៅក្មេងពេក ឬ ចាស់ពេក

❋ គួរប្រមូលគ្រាប់ពូជមកពី

.ដើមឈើយ៉ាងហោចណាស់អោយបាន២០ដើមដែលមានទីតាំងផ្សេងពីគ្នា

.ដើមឈើដែលមានផេណូទីបល្អ

.ដើមឈើដែលអោយផ្លែផ្កានៅក្នុងកំឡុងរដូវផ្លែផ្កាពិតប្រាកដ

.ដើមឈើដែលមានផលិតផលគ្រាប់ច្រើន

❋ វិធីសាស្ត្រនៃការប្រមូលគ្រាប់ពូជ

.ការប្រមូលគ្រាប់ពូជដោយទំរុះ (នៅលើដី)

.ការប្រមូលគ្រាប់ពូជដោយអង្រួនដើម

.ការប្រមូលគ្រាប់ពូជដោយឡើងបេះប្រមូលគ្រាប់ពូជ

.ការប្រើឧបករណ៍ថ្លក់ទាញ

❋ ការហាលនិងការថែរក្សាទុកគ្រាប់ពូជ

.ហាលសំងួតគ្រាប់ពូជដោយពន្លឺព្រះអាទិត្យ១-៣ថ្ងៃទៅតាមភាពជាក់ស្តែងនៃកំរិតនិងដង់ស៊ីតេសំណើមនៅក្នុងគ្រាប់ពូជមុនធ្វើការទុកដាក់

.ពិនិត្យមើលតាមប្រភេទគ្រាប់ដែលត្រូវទុកដាក់

❋ ការធ្វើតិះគ្រាប់ពូជ

.ធ្វើតិះគ្រាប់ពូជនៅកន្លែងប្រមូលគ្រាប់ដោយគ្រាន់តែចិតមើលផ្នែកខាងក្នុង (កូទីលេដុង) ថាតើវានៅល្អ(សាច់គ្រាប់នៅស្រស់មានពណ៌សឬបៃតងស្រស់) ឬក៏ខូចខាតទៅហើយ( សាច់គ្រាប់រលួយឬស្វិត ) ។

.ធ្វើតិះបន្ទាប់ពីប្រមូលគ្រាប់ពូជមកកន្លែងឬស្នាក់ការវិញដោយធ្វើការសាកល្បង បណ្តុះហើយកត់ត្រា ដំណុះអោយបានត្រឹមត្រូវ ។

## V. បច្ចេកទេសបណ្តុះកូនឈើដោយគ្រាប់

### គោលបំណង:

ដើម្បីធានាដល់អ្នកចូលរួម អោយមានជំនាញចាំបាច់ក្នុងការធ្វើប្រព្រឹត្តកម្មគ្រាប់ពូជ ការ សាបគ្រាប់ និង ការប្រើប្រាស់ ។

❖ <u>ការប្រព្រឹត្តកម្មគ្រាប់ពូជ</u>

◊ សាបដោយផ្ទាល់

◊ ទឹកត្រជាក់

◊ ទឹកក្តៅពុះ (សមស្របតាមប្រភេទសំបករឹង)



**ការប្រព្រឹត្តកម្មគ្រាប់ពូជដោយទឹកក្តៅ**

◊ កាត់ ឬ ច្រឹប ឬ ធ្វើឱ្យកកិត

◊ ដុតភ្លើងរោល

❖ <u>កន្លែងដែលត្រូវសាប និងមូលហេតុ</u>

◊ មានរងសាប ថាសសាប ដាក់ក្នុងថង់ផ្ទាល់ ឬ ក្នុងរងផ្សាំ

❖ វិធីសាស្ត្រសាបគ្រាប់ពូជ



✈ **គ្រាប់តូច ហើយស្រាល**

**ការអនុវត្តន៍**

-បាចទឹកដើម្បីធ្វើអោយដីសើម

-លាយគ្រាប់ពូជជាមួយនឹងដីខ្សាច់ស្ងួតល្អ (គ្រាប់ពូជ១ភាគ ដីខ្សាច់២-៣ភាគ )

-ដាក់គ្រាប់ពូជលាយដីខ្សាច់ទៅក្នុងកញ្ជ្រែង ហើយរែងអោយបានស្មើល្អពីលើរងសាប

-បន្ទាប់ពីរែងគ្រាប់ពូជ រែងស្រទាប់ខ្សាច់ល្អយ៉ាងស្តើង(២-៣ម.ម)ពីលើគ្រាប់ពូជ

-ស្រោចទឹកយ៉ាងថ្នមលើរងសាបគ្រាប់ពូជ ដោយប្រុងប្រយត្ន័ ដើម្បីចៀសវាងកុំអោយគ្រាប់ខ្ទាតចេញពីដី ។

✈ **គ្រាប់ពូជមានទំហំមធ្យមទៅខ្លាំង**

**ការអនុវត្តន៍**

-ដាក់គ្រាប់ផ្ទាល់ទៅក្នុងថង់ប្លាស្ទិច ឬ ក្នុងរងបណ្តុះ

-ស្រោចទឹកលើល្បាយដី ដើម្បីអោយវាសើម តែមិនមែនជោគពេកទេ

-គ្របគ្រាប់ដោយដីល្អ ក្នុងជំរៅស្មើនិងអង្កត់ផ្ចិតនៃគ្រាប់ ។

❖ ការថែរក្សា

◊ គ្របកំរាលចំបើង / ស្រោចទឹក / គំរបម្លប់ ដើម្បីរក្សាសំណើមក្នុងរងសាប ឬ ថ្នាលបណ្តុះ ។


HOT WATER TREATMENT
20 l for 5 kg of seed
Boil water
Take off the fire
Immerse seed
Cool overnight
Rinse
SOWING DEPTH
For pots
and
seedbeds
a
a
Eucalyptus
a
a
Pinus
a
a
Big seeds, e.g. Juglans




# VI. ការស្ទូងកូនឈើក្នុងថង់

## គោលបំណង:

ផ្តល់បទពិសោធន៍ជាក់ស្តែង ដល់អ្នកចូលរួម នៅក្នុងការដាំ និងស្ទូងកូនឈើ។

◊ ពេលដែលត្រូវដកស្ទូង(កូនឈើមានស្លឹកពី២-៣សន្លឹក)ធ្វើនៅពេលមេឃស្រទុំឬពេលអាកាសធាតុត្រជាក់ ។

❖ <u>វិធីដកកូនចេញពីរងបណ្តុះគ្រាប់</u>

◊ ស្រោចទឹកកូនឈើលើរងបណ្តុះអោយបានជោគមុននឹងដក

◊ ប្រើចានធំមួយដែលមានទឹកស្អាតសំរាប់ដាក់កូនឈើ

◊ ប្រើសមឈើ ឬឧបករណ៍តូចដើម្បីបំផុសដីឱ្យឫសធូរ ទាញកូនឈើថ្នមៗ

◊ កាន់គល់កូនឈើឱ្យណែន កុំសង្កត់ធ្ងន់ពេក

◊ កាត់តំរឹមឫសណាដែលវែងពេកនិងដាក់កូនឈើទៅក្នុងចានដែលមានទឹកត្រាំ

❖ <u>ការស្ទូងកូនក្នុងថង់</u>






## សកម្មភាពស្ទូងកូនឈើ

◊ ប្រើកូនឈើ ឬ សំភារៈប្រហាក់ប្រហែល ដើម្បីធ្វើរន្ធនៅកណ្ដាលថង់

◊ ដាក់ឫសកូនឈើចូលទៅក្នុងរន្ធដោយមិនធ្វើអោយច្បត់ឫសកូនឈើ

◊ លប់ដី សង្កត់ជុំវិញគល់កូនឈើដោយថ្នមៗ រួចស្រោចទឹក



**ការធ្វើរងដោយប្រើក្តារ**

## VII. <u>បច្ចេកទេសបណ្តុះកូនឈើតាមសរីរាង្គ</u>

### ១.<u>អត្ថប្រយោជន៍</u>

ការបណ្តុះកូនឈើតាមសរីរាង្គគេអាចធ្វើទៅបានលើប្រភេទឈើហូបផ្លែ ឈើសំណង់ ឈើអុស ឈើសំរាប់លំអទីក្រុង ។ល។ អត្ថប្រយោជន៍របស់វាមានដូចតទៅ:

-រក្សាបាននូវពូជកំណើត

-ឆាប់បានផ្តល់ផល

-ងាយស្រួលក្នុងការដឹកជញ្ជូនយកទៅដាំ

-ចំណេញពេលវេលា

### ២.<u>វិធីសាស្ត្រនៃការបណ្តុះកូនឈើតាមសរីរាង្គ</u>

◊ ការបណ្តុះកូនឈើដោយមែក

◊ ការបណ្តុះកូនឈើដោយគល់ ឬ ស្ទុំ

◊ ការបណ្តុះកូនឈើដោយផ្សាំ

### ២.១ <u>ការបណ្តុះកូនឈើដោយមែក</u>

ប្រភេទឈើខ្លះអាចធ្វើការបណ្តុះដោយមែកដូចជា: ប្រេងខ្យល់ អាកាស្យា ផ្ទង់ ម៉ៃសាក់។ល។ ការបណ្តុះនេះគេអាចធ្វើបានដោយកាត់មែកឈើដែលមានប្រវែងពី ៣៥ស.ម-៤៥ស.ម ហើយមានពន្លកមែកចំនួនពីរយ៉ាងតិចពីចុងមែកប្រវែងបី១០-១៥ស.ម។គេត្រូវដាំក្នុងទីតាំងផ្តេកបន្តិចទៅក្នុងដីសើមប្រវែងប្រមាណ

៣ភាគ៤ នៃប្រវែងមែក ហើយមិនត្រូវដាំបញ្ច្រាស់មែកឡើយ ព្រោះបណ្តាលអោយការលូតលាស់ផ្នែកឫស ខូចខាត ។




ការបណ្តុះកូនឈើដោយមែក

### ២.២.ការបណ្តុះកូនឈើដោយគល់ ឫស្ទំ

ការបណ្តុះកូនឈើដោយគល់ឫស្ទុំ គឺត្រូវជ្រើសរើសកូនឈើក្នុងថ្នាលដែលមានគល់ទំហំ ប្រមាណជា ១-៣ស.ម ទើបអាចស្ទុំបាន។ គល់ត្រូវមានប្រវែងពី ២០-២៥ស.ម គឺប្រមាណ ៨០% នៃឫស និង ២០% នៃគល់ ហើយមានបន្ទាត់ផ្ចិតគល់ប្រហែលពី ១-៣ស.ម។ ការដាំស្ទុំត្រូវដាំបញ្ឈរត្រង់ដោយបន្សល់ឫសពីដី ប្រវែងប្រហែល ៣-៥ ស.ម ។



## ២.៣.ការដាំឈើដោយផ្សាំ

ការបណ្តុះកូនឈើដោយផ្សាំ គេអាចធ្វើបានតែប្រភេទឈើហូបផ្លែតែប៉ុណ្ណោះ ។

- ការផ្សាំដោយបណ្តុះឫស



- ការផ្សាំដោយភ្ជាប់មែក និងមែក




- ការផ្សាំដោយភ្ជាប់ភ្នែក និង ភ្នែក ឬ ពន្លកមែក



## VIII. ការថែទាំកូនឈើ

### គោលបំណងៈ

ដើម្បីពង្រឹងជំនាញអ្នកចូលរួមនៅក្នុងការថែទាំ និង គ្រប់គ្រងកូនឈើនូវគ្រប់រូបភាព ក្នុងថ្នាល។

◊ ការស្រោចទឹកកូនឈើ(ស្រោចនៅពេលណា ចំនួនប៉ុន្មាន ហើយប៉ុន្មានដងក្នុង១ថ្ងៃ ត្រួតពិនិត្យមើលសំណើមដីបែបណា )

◊ ការធ្វើគំរបម្លប់ ជាទូទៅគំរបម្លប់ធ្វើអោយពន្លឺថ្ងៃចូលបាន៥០%(ពេលប្រើ ពេលដកចេញមិនប្រើ)

◊ ធ្វើការសំអាតស្មៅចង្រៃអោយបានទៀងទាត់ មុននឹងដកត្រូវស្រោចទឹក ហើយដក ដោយថ្នមៗ

◊ ផ្លាស់ប្តូរទីតាំងកូនឈើអោយបាន២-៣ដងក្នុង១ឆ្នាំ ហើយកាត់ឫសដែលចេញពីថង់។ ញែកកូនឈើតូច និងកូនឈើធំចេញពីគ្នាដើម្បីឱ្យកូនឈើតូចលូតលាស់បានល្អ ។



**សកម្មភាពប្តូរទីតាំងកូនឈើ**

## ROOT PRUNING OF POTTED SEEDLINGS



Correct: timing permits "shocking"



False: roots are too long



Root pruning with pruning shears



Root pruning with trowel



Root pruning with wire (e.g. piano wire)



PRUNE TAPROOT TO DEVELOP STRONGER ROOT SYSTEM

## PREPARATION FOR PLANTING OUT

ការរៀបចំសំរាប់យកទៅដាំ

### Grading



| 1st class | 2nd class | Plant rejected |
|---|---|---|
| ថ្នាក់ ១ | ថ្នាក់ ២ | |

### Watering

ការស្រោចទឹក



The night before planting in the field, water the seedlings thoroughly

### PACKING



Hold the bags and not the seedlings



Never pull by the shoots



Use trays and boxes for transport



Don't tie the pots with rope

◊ ការធ្វើអោយកូនឈើរឹងមាំជាមុននៅក្នុងថ្នាល វាជាការសំខាន់ណាស់ ដើម្បីធ្វើ អោយការលើកដាក់ ដឹកជញ្ជូននិងការយកកូនឈើទៅដាំមានអត្រារស់ខ្ពស់។ ដូចនេះ យើងត្រូវៈ

- យកគំរបម្លប់ចេញយ៉ាងតិចអោយបានមួយខែមុន
- ថង់កូនឈើត្រូវធ្វើការផ្លាស់ប្តូរទីតាំង អោយបានពី ២-៣ សប្តាហ៍មុននឹងយកទៅដាំ ហើយកាត់ឫសណាដែលចេញពីថង់ដោយប្រុងប្រយត្ន័

☆ <u>សារសំខាន់នៃការកាត់ឫស</u>

- ជំរុញអោយឫសរយាងមានការលូតលាស់
- បង្កើនការលូតលាស់អោយបានស្មើគ្នាដល់កូនឈើ
- ធ្វើអោយកូនឈើបានរឹងមាំមុននឹងដកចេញពីថ្នាល

<u>**ការអនុវត្តន៍**</u>

- លើកថង់កូនឈើឡើងដកចេញពីថ្នាល ប្រសិនបើឫសលយចេញពីបាតថង់ ត្រូវប្រើកាំបិតមុត ឬ កន្ត្រៃ ដើម្បីកាត់ឫសនីមួយៗចេញ
- ចំពោះកូនឈើដែលលូតលាស់លឿនជាងគេ ត្រូវកាត់ស្លឹកវាចេញខ្លះ
- រៀងរាល់កន្លះខែ ត្រូវលើកកូនឈើចេញដើម្បីការពារកុំអោយឫសដុះជាប់នឹងដី ក្នុងរង
- មួយសប្តាហ៍មុនដកកូនឈើយកទៅដាំ គួរកាត់ឫសជាចុងក្រោយ ។
- កាត់បន្ថយការស្រោចទឹក ពី១-២សប្តាហ៍ និងបញ្ឈប់ការដាក់ជីពី ៤-៦សប្តាហ៍ មុននឹងយកទៅដាំ ។

◊ ការធ្វើរធ្វើលនៃកូនឈើផ្សាំ

◊ ការកាត់តឹមកូនឈើដែលធំពេកដើម្បីឱ្យកូនឈើតូចមានលទ្ធភាពលូតលាស់បាន ឬ ទុកក្នុងថ្នាលបន្តទៀត

◊ ការដាក់ជីកូនឈើ

-បន្ទាប់ពីស្ទួងបាន ពី៤-៥សប្តាហ៍មក កូនឈើត្រូវដាក់ជីក្នុងមួយសប្តាហ៍ដាក់ជីម្តង រហូតដល់ ៧សប្តាហ៍ ។

-ការដាក់ជីលើកចុងក្រោយ ប្រើតែជីដែលមាន ផូស្វ័រ និង ប៉ូតាស្យូម ពីព្រោះវានិងជួយពង្រឹងកូនឈើ ។

-បរិមាណជីដែលប្រើត្រូវលាយទឹក ហើយសូលុយស្យុងជីនេះមិនត្រូវអោយច្រើនជាង ៣ក្រាម ក្នុងទឹកមួយលីត្រ ។ ប្រើធុងផ្កាឈូកស្រោចនៅពេលព្រឹក និង ល្ងាច ។

-ប្រើជីរួចត្រូវស្រោចទឹកស្អាតលើកូនឈើដោយប្រើទឹកយ៉ាងតិច ២លីត្រ ក្នុង១ម[២] ។ ការដាក់ជីចុងក្រោយគួរតែបញ្ចប់នៅពីរសប្តាហ៍មុនដកកូនឈើ ។

**កាលវិភាគនៃការដាក់ជី**

| ការដាក់ជី | ជា គ.ក NPK ក្នុងកូនឈើ១០០០ដើម |
|---|---|
| -លើកទី១ | ០,៥ |
| -លើកទី២ | ១,០ |
| -លើកទី៣ | ១,៥ |
| -លើកទី៤ | ២,០ |
| -លើកទី៥ | ២,០ |
| -លើកទី៦ | ១,០ |
| -លើកទី៧ | ១,០ |

◊ អនាម័យថ្នាល

-ល្បាយជីត្រូវតែប្រព្រឹត្តកម្ម

-ជៀសវាងប្រើទឹកដែលមានមេរោគយកទៅស្រោចកូនឈើ

-ជៀសវាងអោយស្មៅចង្រៃដុះក្នុងថ្នាលជំរះស្មៅចង្រៃឬស្មៅព្រៃក្នុងថ្នាលបណ្តុះដាក់បំពេញរណ្តៅ

-ជៀសវាងអោយទឹកហូរដោយសេរីក្នុងថ្នាលបណ្តុះ

-ត្រូវដកចោលនូវកូនឈើដែលឆ្លងជំងឺដោយសត្វល្អិត និង មេរោគ

-កុំទុកកូនឈើចាស់នៅក្នុងថ្នាលបណ្តុះកូនឈើ

-សំអាតថ្នាលជារៀងរាល់ថ្ងៃដោយប្រមូលសំរាមកូនឈើងាប់ ថង់ប្លាស្ទិច ហើយដុត ចោល

-ឧបករណ៍ប្រើប្រាស់ទាំងអស់ត្រូវសំអាត និង រក្សានៅកន្លែងមួយយ៉ាងត្រឹមត្រូវ

◊ ការពារថ្នាលបណ្តុះ

នៅពេលខ្យល់ខ្លាំងអាចមានឥទ្ធិពលបំផ្លាញការលូតលាស់របស់កូនឈើ ដូចជា:

-ឫសអាចខូចដោយការប៉ះទង្គិចនៃដើមរុក្ខជាតិជាពិសេសនៅពេលដីសើមនិងទន់ ។

-រហែកស្លឹក ជាំស្លឹក និងខ្លោចស្លឹក ធ្វើអោយកូនឈើបន្ថយសមត្ថភាពធ្វើរស្មី សំយោគ និង ងាយមានជំងឺបៀតបៀន ។

-ការរំហួតទឹកកើនឡើង ដែលទាមទារការស្រោចទឹកអោយបានច្រើន

-ពេលភ្លៀងធ្លាក់ខ្លាំងក៏អាចបំផ្លាញកូនឈើនៅតូចនិង ហូរនាំដីចេញពីថ្នាលបណ្តុះ

◊ សត្វល្អិត និងជំងឺ

ប្រសិនបើយើងធ្វើអនាម័យថ្នាលអោយបានត្រឹមត្រូវ ការកកើតមាននូវការបំផ្លាញពី សត្វល្អិត និងមេរោគផ្សេងៗត្រូវបានកាត់បន្ថយ ម្យ៉ាងទៀតយើងអាចប្រើថ្នាំសំ លាប់សត្វល្អិត និង សំលាប់ពពួកផ្សិតក៏ត្រូវបានកាត់បន្ថយដែរ។

◊ ការកត់ត្រា

ការកត់ត្រាបានត្រឹមត្រូវនិងរាល់ថ្ងៃជាប្រចាំ អាចជួយយើង:

-តាមដានគ្រាប់ពូជពីកំណើតចំនួនគ្រាប់ពូជបណ្តុះ

-ដើម្បីប៉ាន់តំលៃផលិតផលកូនឈើនិងកំណត់តំលៃកូនឈើដោយពិនិត្យដើមទុន ទាំងអស់

-ធ្វើអោយប្រសើរដល់ការគ្រប់គ្រង និង ផលិតកូនឈើមានគុណភាព ។

# IX. ការដាំកូនឈើ

## ១_ការងារដែលត្រូវរៀបចំមុនពេលដឹកកូនឈើទៅដាំ

### ក_ចំពោះកូនឈើបណ្ដុះក្នុងថង់ផ្លាស្ទិក

◊ ការកាត់ឫសកូនឈើគួរត្រូវធ្វើឡើងនៅថ្នាលបណ្ដុះក្នុងរយៈពេលពី ២ទៅ៣សប្ដាហ៍ មុនយកទៅដាំ។ ត្រូវកាត់ឫសណាដែលដុះចេញមកក្រៅថង់ចូលទៅក្នុងដីដោយប្រើកាំបិត ឬ កន្ត្រៃដែលមុត និង ដោយប្រុងប្រយ័ត្ន នៅពេលដែលលើកថង់កូនឈើឡើង ចំពោះកូនឈើដែលបណ្ដុះក្នុងថង់យូរ យើងត្រូវកាត់ស្លឹកឬមែកនិងឫសរបស់វាចេញឱ្យបានច្រើន (កាត់ប្រព័ន្ធឫសកែវដែលដុះពត់ កែងចេញក្រៅដើម្បីឱ្យវាត្រង់) ។

◊ កាត់ស្លឹកនិងមែកណាដែលមិនបានការមួយផ្នែកចេញជាចាំបាច់។ នៅពេលកូនឈើបង្ហាញនូវសញ្ញាណណាមួយនៃការស្វិតស្រពោននោះគប្បី កាត់ស្លឹករបស់វាពី ៥០%-៨០%ចេញដោយប្រើកន្ត្រៃ (ត្រូវរក្សាទុកត្រួយ ពន្លកចុងបង្អស់ឱ្យនៅដដែល) ។

◊ មិនត្រូវស្រោចទឹកកូនឈើមុនពេលដឹកជញ្ជូនមួយថ្ងៃឡើយ

◊ ការដឹកជញ្ជូនទៅកាន់កន្លែងដាំ គប្បីធ្វើនៅពេលមេឃស្រទុំ បើកយឺតៗ ហើយរថយន្តគួរមានដំបូល ឬ គំរបតង់ឬស្បៃ ដើម្បីជៀសវាងកុំឱ្យខ្យល់បក់ខ្លាំងទៅលើកូនឈើ និងបែកដី ។

◊ កូនឈើដែលដឹកជញ្ជូនដល់កន្លែងដាំគួរត្រូវទុកដាក់នៅក្រោមម្លប់ និង ស្រោចទឹកឱ្យបានសមស្របក្នុងករណីទុកពី ២ថ្ងៃឡើងទៅ។



### ខ. កូនឈើបណ្ដុះក្នុងរងផ្សាំ

❖ កូនឈើដែលបណ្ដុះក្នុងរងផ្សាំ មានអត្ថប្រយោជន៍ក្នុងការកាត់បន្ថយតំលៃនៃការផលិតកូន និង អាចផលិតកូនបានច្រើនសំរាប់ដាំជាចំការធំៗ និង ជួយបន្ធូរបន្ថយដល់ការដឹកជញ្ជូន ។

◊ គួរត្រូវគាស់កូនឈើចេញពីរងផ្សាំនៅពេលមេឃស្រទុំ បន្ទាប់ពីស្រោចទឹកដាក់រងរួច

◊ កូនឈើដែលបានគាស់ចេញពីរងផ្សាំ គួរយកទៅដាក់ក្នុងទឹកលាយភក់ ពោលគឺដាក់នៅក្នុងរណ្ដៅដែលមានទឹក និងដី ហើយនៅពេលដឹកទៅដាំត្រូវដាក់នៅក្នុងថង់បិទជិត ។

◊ ប្រភេទឈើសំណង់មួយចំនួនអាចត្រូវបានគេយកទៅដាំដោយកាត់គល់ (ដើមម៉ៃសាក់....) ពោលគឺកាត់ចេញផ្នែកខាងលើដោយទុកតែប្រមាណ ១០ស.មពីគល់ និងទុកផ្នែកខាងឫសប្រមាណ ២០ស.ម ពីគល់ដែលសរុបនៅសល់ទាំងអស់មានប្រវែង ៣០ស.ម។ ហើយកូនឈើមួយចំនួន (ដើមកន្ទុំថេត...) អាចត្រូវបានយកទៅដាំដោយគល់ដើមផងដែរ ពោលគឺពេលគាស់ចេញពីរងផ្សាំ ស្លឹកនិងមែកត្រូវបានកាត់ចេញទុកតែចុងត្រួយ ហើយឫសកែវដែលវែងពេក និងឫសស្ទៃមួយចំនួនក៏ត្រូវកាត់ចេញដែរ ។

◊ ត្រូវដឹក និង ទុកដាក់កូនឈើនៅក្រោមម្លប់មុនពេលយកទៅដាំ

◊ ត្រូវរក្សាកូនឈើឱ្យនៅសើម និង យកទៅដាំឱ្យបានភ្លាមៗបន្ទាប់ពីយកចេញពីថ្នាលបណ្ដុះ ។






### ២. ការរៀបចំដី

◊ ត្រូវដាំដើមឈើនៅលើដីដែលភ្ជួររាស់ហើយ ឬក៏នៅលើផ្ទៃដីកសិដ្ឋាន

◊ កាប់ឆ្ការយកគុម្ពោតព្រៃចោលនៅតាមព្រំដី

### ៣. គំលាតដាំ

◊ ការកំនត់គំលាតដំបូងនៃដើមឈើនៅក្នុងចំការឈើគឺអាស្រ័យទៅលើគោលបំណងរួមនៃចំការឈើ និង ប្រភេទឈើដែលត្រូវដាំ ។ ជាទូទៅគំលាតសំរាប់ឈើសំណង់ (4m x 4m) និង គំលាតសំរាប់ឈើអុស (2m x 2m) ។ នៅលើទីជម្រាល ជួរដើមឈើត្រូវរត់តាមខ្សែវណ្ឌចន្លោះរវាងដើមឈើ

មួយទៅមួយ និងចន្លោះពីជួរមួយទៅជួរមួយត្រូវបានរៀបចំឡើងដោយប្រើកូនឈើវាយឡោះ ឬ ក៏ប្រើខ្សែដោយកំនត់យកប្រវែងតាមដែលយើងត្រូវការ ។

## ៤. ជីករណ្ដៅ

◊ ទីតាំងដាំនៃរណ្ដៅនីមួយៗ គួរត្រូវបានសំអាតរុក្ខជាតិដែលគ្មានប្រយោជន៍ និង ព្រៃគុម្ពោតឱ្យបានទំហំ 1m x 1m មុនពេលជីករណ្ដៅដាំ ។

◊ ទំហំរណ្ដៅមានសារៈសំខាន់បំផុត ដោយយកទំហំយ៉ាងតិច 0.3m x 0.3m x 0.3m

◊ ត្រូវជីករណ្ដៅឱ្យបានល្អដោយប្រើចប ឬ ប៉ែល

◊ ត្រូវយកអាចម៍ដីដែលជីកបានគរក្បែររណ្ដៅនីមួយៗដោយដាក់ស្រទាប់លើមួយផ្នែកនិងស្រទាប់ក្រោមមួយផ្នែក ។

◊ បន្ទាប់ពីជីករណ្ដៅដាំហើយ គួរដាំឱ្យបានឆាប់ជៀសវាងកុំឱ្យដីស្ងួតរណ្ដៅទាន់

## ៥. ការដាំ

◊ ត្រូវដឹកជញ្ជូន និងរក្សាទុកកូនឈើក្រោមម្លប់នៅតំបន់ដែលត្រូវដាំ (មិនត្រូវទុកកូនឈើឱ្យត្រូវកំដៅថ្ងៃយូរនៅមុនពេលយកទៅដាំ) ។

◊ អ្នកដាំត្រូវមានចប,ប៉ែលឬឈើខ្លីមួយដែលប្រើប្រាស់ក្នុងការបំបែកដី និងប្រើប្រាស់សំរាប់ប្រមូលអាចម៍ដីបំពេញទៅក្នុងរណ្ដៅ។

◊ ពេលដាំត្រូវហែកយកថង់ប្លាស្ទិកចេញ (ប្រមូលថង់យកទៅដុតចោល)

◊ ត្រូវយកដីស្រទាប់លើមកលុបបាតរណ្ដៅ រួចយកកូនឈើដែលហែកថង់ចេញមកដាក់ចូលក្នុងរណ្ដៅឱ្យបានថ្នមៗដោយយកដៃម្ខាងទ្របាត ហើយដៃម្ខាងទៀតកាយដីមកលុប រហូតដល់កូនឈើមានលំនឹងទើបដកដៃដែលទ្របាតចេញ។

◊ យកដីរាយៗ ដែលបានមកពីការជីករណ្ដៅមកដាក់បំពេញជុំវិញកូនឈើដែលបានដាំ ហើយបង្ហាប់ឱ្យបានណែនល្អ ។

◊ ត្រូវកប់លុបគល់នៃកូនឈើអោយស្មើនឹងផ្ទៃដី ឬក៏ទាបជាងផ្ទៃដីបន្តិច ។


៣តឹក
៣តឹក
២_៣តឹក
រូប ក
ដីស្រទាប់លើ
ដីស្រទាប់ក្រោម
រូប ខ
រូប គ
រណ្តៅលើដីជំរាល
ជំរៅរណ្តៅ
រូប ឃ


ដីកំប៉ុស្ត ១គីឡូក្រាម
ដីស្រទាប់លើ
ដីស្រទាប់ក្រោម
១
២
៣
៤
៥

◊ ចំពោះប្រភេទឈើដាំដោយគល់ឫស (root shoot cuttings) ឬដោយដើមគល់ (bare root) រណ្តៅនីមួយៗត្រូវចាក់បំពេញដោយដីរាយៗ ។

◊ បន្ទាប់មក ត្រូវកាយដីរណ្តៅដោយដៃ ឬចប ហើយដាំកូនឈើត្រឹមគល់ឫសរបស់វា ។

◊ ក្រោយមកត្រូវយកដៃបង្ហាប់ដីដែលលុបនៅជុំវិញគល់ឫសនោះ

◊ សំខាន់បំផុតគឺថា ឫសរបស់វាត្រូវដាក់ត្រង់ទៅក្នុងរណ្តៅ ហើយកូនឈើមិនត្រូវបានរុញខ្លាំងទៅក្នុងដី ហើយបន្ទាប់មកលុបដីជុំវិញគល់ឱ្យណែនល្អ ។

✵ ប្រសិនបើអាចធ្វើទៅបាន គួរយកជីកំប៉ុសទៅដាក់តាមរណ្តៅកូនឈើនីមួយៗប្រមាណ 2kg ក្នុង ១ រណ្តៅ ដើម្បីជួយជំរុញកូនឈើដែលបានដាំដំបូងនោះឱ្យមានការលូតលាស់បានល្អ ។

## ៦. ការថែរក្សា

◊ ប្រសិនបើអាចធ្វើបាន ត្រូវស្រោចទឹកលើកូនឈើ បន្ទាប់ពីដាំហើយ

◊ ដាក់សំរាម ឬស្មៅជុំវិញគល់កូនឈើដែលបានដាំហើយថ្មីៗ ព្រោះវាអាចផ្តល់ឱ្យដីនូវម្លប់ និង កាត់បន្ថយការបាត់បង់សំណើម និងជំរុញឱ្យមានការលូតលាស់បានល្អ ។




◊ កូនឈើដែលបានដាំហើយថ្មីៗ គួរត្រូវបានការពារកុំឱ្យសត្វពាហនៈ ចូលបំផ្លាញ

◊ ការពារកុំឱ្យមានភ្លើងឆាបឆេះ

◊ បើអាចធ្វើបានត្រូវស្រោចទឹកឱ្យបានទៀងទាត់ និងប្រើជីគីមី ឬជីកំប៉ុស្ត ព្រោះវានឹងជួយឱ្យមានអាត្រារស់ និង ការលូតលាស់បានល្អ ។

◊ រៀងរាល់ការដាំកូនឈើគួរតែធ្វើឡើងនៅរដូវវស្សា នៅពេលដែលដីទទួលសំណើមគ្រប់គ្រាន់ដើម្បីធានាដល់អត្រារស់ និងការលូតលាស់របស់កូនឈើ ។

## X-<u>អំពីជី</u>

ជីមានពីរប្រភេទគឺ ជីសរីរាង្គ (ជីធម្មជាតិ) និង អសរីរាង្គ (ជីគីមី) ។

### ១-<u>ជីអសរីរាង្គ</u>

ជីដែលសំយោគឡើងដោយឧស្សាហកម្មដែលមានធាតុសកម្មខ្ពស់ ។ ជីអសរីរាង្គរួមមានៈ

**ក-<u>ជីទោល</u>** :

ជីដែលមានធាតុផ្សំតែ មួយមុខ ដូចជា អ៊ុយរ៉េ (N 46%), សូពែផូស្វាត (P 20%), ប៉ូតាស្យូមក្លរួ (K 60%)

**ខ-<u>ជីសមាសមិនគ្រប់មុខ</u>:**

ជីដែលមានធាតុផ្សំតែ ២មុខ ដូចជា DAP (18.46.0), 16.20.0

**គ-<u>ជីសមាសគ្រប់មុខ</u>:**

ជីដែលមានធាតុផ្សំ ៣មុខ ដូចជា 15.15.15, 17.17.17, 13.13.13, 16.16.8.13S

**ឃ-<u>ជីលាយ</u>:**

អ៊ុយរ៉េ (N 46%) + DAP (18.46.0)

### ២-<u>ជីសរីរាង្គ</u>

ជីដែលកើតឡើងដោយធម្មជាតិ ។ ជីសរីរាង្គរួមមាន :

- ជីលាមកសត្វ (គោ ក្របី ជ្រូក មាន់ ប្រចៀវ ..។ល។)
- ជីកំប៉ុស្ត
- ជីស្រស់ (ស្លឹករុក្ខជាតិ ស្មៅ ពពួកអំបូរសណ្តែក ......។ល។)
- កាកសំណល់ផ្ទះបាយ និង កាកសំណល់កសិកម្ម (រុក្ខជាតិ សត្វ)
- កាកសំណល់ចង្ក្រានជីវឧស្ម័ន

# XI -ការធ្វើជីកំប៉ុស្ត

## ១-តើកំប៉ុស្តជាអ្វីនៅ?

នៅក្នុងធម្មជាតិរុក្ខជាតិនានានិងពពួកសត្វទាំងឡាយដែលបានស្លាប់ ហើយត្រូវបានធ្វើអោយរលួយដោយសារពពួកមីក្រូសរីរាង្គ (ផ្សិត បាក់តេរី វីរុស និងដង្កូវក្នុងដី ។ល។) ដោយមានជំនួយពីទឹក ពន្លឺព្រះអាទិត្យ ខ្យល់ និងពេលវេលា ។ ដំណើរការពុករលួយនៃសារធាតុ សរីរាង្គ (រុក្ខជាតិ និងពពួកសត្វ) បានក្លាយទៅជាមមោត ដែលសំបូរទៅដោយជីជាតិដើម្បីផ្តល់អោយដំណាំ និងរុក្ខជាតិនានាសំរាប់ការលូតលាស់ និងផ្កាផ្លែ។

## ២-តើអ្វីបានកើតឡើងនៅពេលធ្វើកំប៉ុស្ត?

កំប៉ុស្តគឺជាការបំបែកធាតុនៃលក្ខណះគីមី និង លក្ខណះរូបនៃសារធាតុសរីរាង្គ។ កំប៉ុស្តបញ្ចេញជីជាតិដែលមានដល់រុក្ខជាតិ។ សត្វល្អិត ផ្សិត និងពពួកបាក់តេរីបាននាំគ្នារំលាយសារធាតុសរីរាង្គក្នុងអំឡុងពេលនៃការបំបែកធាតុ (ការធ្វើអោយពុករលួយ) ។ ពួកវាស៊ីសារធាតុសរីរាង្គមុនវាក្លាយជាកំប៉ុស្ត ។ ពួកវាត្រូវការខ្យល់ និង ទឹកដើម្បីធ្វើអោយកំប៉ុស្តមានដំណើរការល្អ ។

មានវិធីសាស្ត្រ ២បែបនៃការផលិតកំប៉ុស្តគឺ កំប៉ុស្តមានខ្យល់ និងកំប៉ុស្តគ្មានខ្យល់។ វិធីសាស្ត្រកំប៉ុស្តគ្មានខ្យល់ផ្តល់អុកស៊ីហ្សែនតិចតួចដល់ពពួកមីក្រូសរីរាង្គដែលបានរំលាយសារធាតុសរីរាង្គក្នុងគំនរកំប៉ុស្ត។ ចំណែកឯវិធីសាស្ត្រកំប៉ុស្តមានខ្យល់ផ្តល់អុកស៊ីហ្សែនច្រើនដល់ពពួកមីក្រូសរីរាង្គ។ ភាពខុសគ្នាដ៏សំខាន់រវាងវិធីសាស្ត្រទាំងពីរគឺពេលវេលា និងក្លិនរបស់កំប៉ុស្ត។ កំប៉ុស្តគ្មានខ្យល់គឺរលួយយឺតក្រចានប្រើតាមធម្មតាវាត្រូវការពេលវេលា ៩ខែ។ កំប៉ុស្តគ្មានខ្យល់ប្រើកំលាំងពលកម្មតិច ព្រោះរណ្តៅត្រូវបានគេដាក់បំពេញសារធាតុសរីរាង្គ គ្របនិងទុកចោលដោយគ្មានអ្នកថែរក្សា ឧស្ម័នដែលមានក្លិនមិនល្អ (មេតាននិងស្ពាន់ធ័រ) ជារឿយៗបានកើតឡើង ។ កំប៉ុស្តដែលមានខ្យល់ អាចប្រើការបានក្នុងរយះពេលដ៏ខ្លីគឺ ៤០ថ្ងៃ ប្រសិនបើយើងប្រែត្រឡប់វាយ៉ាងទៀងទាត់ កំប៉ុស្តដែលមានខ្យល់ត្រូវការត្រួតពិនិត្យអោយបានទៀងទាត់នូវសីតុណ្ហភាពដើម្បីធានាដល់លក្ខខណ្ឌ័ប្រសើរសំរាប់មីក្រូសរីរាង្គដែលកំពុងដំណើរការ។ យើងនិងពិភាក្សាការធ្វើកំប៉ុស្តដែលមានខ្យល់ វាពុករលួយលឿនឆាប់បានប្រើ និង អាចជឿជាក់បាន ។

ដំណាក់កាលផ្សេងពីគ្នាពាក់ព័ន្ធទៅលើការធ្វើអោយមានសីតុណ្ហភាពកើតឡើងក្នុងអំឡុងពេលនៃការធ្វើកំប៉ុស្ត។ កំដៅបានមកពីការកើនឡើងយ៉ាងរហ័សនូវចំនួននៃមីក្រូសរីរាង្គ ពួកវាធ្វើការយ៉ាងខ្លាំង និងបង្កបង្កើតកូនចៅដែលនាំអោយមានកំដៅដូចពេលដែលមនុស្សយើងធ្វើការ ពួកគេក្តៅ ស្រេកទឹក និងត្រូវការខ្យល់បរិសុទ្ធ និងទឹកច្រើន ។ ការធ្វើកំប៉ុស្តអោយបានល្អគឺមានអ្វីៗទាំងអស់ពីការកើតឡើងនូវជំរកដ៏ត្រឹមត្រូវដើម្បីអោយមីក្រូសរីរាង្គអាចបង្កបង្កើតកូនចៅ និង ធ្វើការយ៉ាងខ្លាំង (រំលាយសារធាតុសរីរាង្គ) ។ នៅដំណាក់កាលទី១ ពី២៤ ទៅ ៤៨ម៉ោង ស៊ីតុណ្ហភាព កើនឡើងដល់ ៤០-៥០អង្សាសេ ដែលធ្វើអោយបាត់បង់ជាតិស្ករ និង សារធាតុដទៃផ្សេងទៀត ។

នៅដំណាក់កាលទី២ នៅពេលដែលសីតុណ្ហភាពកើនពី ៥៥-៦៥ អង្សាសេ មីក្រូសរីរាង្គដំបូងបានងាប់ ហើយផ្សេងទៀតបានប្រែប្រួលទៅតាមកំដៅដើម្បីចាប់ផ្តើមបំបែករបស់ដែល រឹងក្រលួយ ដូចជាសាច់ឈើ ។ល។ សីតុណ្ហភាពគួរឡើងដល់កំរិតខ្ពស់បំផុត ៧០អង្សាសេ រយះពេល ៣ថ្ងៃ ដើម្បីកំចាត់ជំងឺរុក្ខជាតិ និង គ្រាប់ស្មៅមិនអោយដុះតទៀតបាន ។ ការរក្សាសីតុណ្ហភាពរវាង ៥៥-៦៥ អង្សាសេ តាមតែអាចធ្វើទៅបាន គឺជាវិធីសាស្ត្រដែលរហ័សបំផុតដើម្បីផលិតកំប៉ុស្តព្រោះនេះជាដំណាក់កាលនៅពេលដែលមីក្រូសរីរាង្គដែលមានសមត្ថភាពកំពុងធ្វើការបំបែករបស់ដែលរឹងដើម្បីរំលាយវា ។ ការត្រឡប់គំនរកំប៉ុស្តដើម្បីបញ្ចូលខ្យល់អុកស៊ីហ្សែន និង ធានាអោយបាននូវល្បាយស្មើគ្នា និង ការរក្សាសំណើមអោយបានពី ៤០-៦០ ភាគរយ ដើម្បីធ្វើអោយប្រសិទ្ធិភាពនៃការធ្វើជីកំប៉ុស្តមានលក្ខណះដ៏ប្រសើរបំផុត ។ ដំណាក់កាលចុងក្រោយដែលក្នុងនោះ សីតុណ្ហភាពនៅសល់ក្រោម ៤០អង្សាសេ កំប៉ុស្តអាចប្រើការបានហើយព្រោះ ពពួកបាក់តេរីនិងផ្សិតដែលជួយកំចាត់ជំងឺរុក្ខជាតិ ព្រមទាំងពពួកសត្វជន្លេនក៏បានចូលមកនៅខាងក្នុងគំនរកំប៉ុស្តផងដែរ ។ កំប៉ុស្តដែលល្អគួរតែកំប៉ុស្តដែលបានពុករលួយល្អ ។ កំប៉ុស្តមិនទាន់ពុករលួយល្អអាចធ្វើអោយដំណាំខូចបាននៅពេលដែលយើងប្រើវា ។ ការដាំដំណាំជាមួយនិងកំប៉ុស្តដែលមិនទាន់ពុករលួយល្អជារឿយៗធ្វើអោយដំណាំប្រែជាពណ៌លឿង ព្រោះរុក្ខជាតិមិនអាចទទួលបានជីជាតិដែលវាត្រូវការ ។ ដើម្បីអោយដឹងថាកំប៉ុស្តអាចប្រើការបាន ដំបូងយើងត្រូវយកកំប៉ុស្តសើមនោះចំនួន ២ក្តាប់ដាក់ទៅក្នុងថង់មួយ បិទមាត់ថង់ទុកវានៅកន្លែងងងឹត និង ត្រជាក់ ។ ក្រោយរយះពេល ២៤ម៉ោង យើងបើកថង់នោះ ប្រសិនបើគ្មានក្លិនឬកំដៅនៅពេលនោះទេ បានសេចក្តីថាកំប៉ុស្តរបស់យើងអាចប្រើការបានហើយ។

### ៣_តើកំប៉ុស្តមានសារធាតុចិញ្ចឹមអ្វីខ្លះសំរាប់ដំណាំ?

ជីកំប៉ុស្តផ្តល់ទៅអោយជីនូវសារធាតុចិញ្ចឹម ១៣មុខ ដែលដំណាំត្រូវការៈ

* សារធាតុចិញ្ចឹមដែលដំណាំត្រូវការច្រើនរួមមាន អាសូ៊ត (N), ផូស្វាត (P), ប៉ូតាស្យូម (K)
* សារធាតុចិញ្ចឹមដែលដំណាំត្រូវការកំរិតមធ្យមរួមមាន កាល់ស្យូម(Ca), ម៉ាញ៉េស្យូម(Mg), ស្ពាន់ធ័រ (S)
* សារធាតុចិញ្ចឹមដែលដំណាំត្រូវការកំរិតទាបរួមមាន ដែក(Fe), ទង់ដែង(Cu), ស័ង្កសី(Zn), ក្លរ(Cl), មូលីបដែន(Mo), បរ(B), ម៉ង់កាណែស(Mn)។
* ចំណែកឯសារធាតុដែលចាំបាច់ ៣មុខទៀតរួមមាន កាបូន(C), អ៊ីដ្រូហ្សែន(H), និងអុកស៊ីហ្សែន(O) ដែលដំណាំអាចស្រូបបានពីទឹក និង ខ្យល់អាកាស។

## មុខងារនៃសារធាតុចិញ្ចឹមដែលដំណាំត្រូវការច្រើន និងរោគសញ្ញានៃកង្វះជីជាតិ

| សារធាតុ | មុខងារ | រោគសញ្ញានៃការខ្វះជីជាតិ |
|---|---|---|
| អាស៊ូត (N) | បង្កើនការលូតលាស់ដល់ដំណាំ ការបែកគុម្ពច្រើន ជំរុញដល់ការចេញផ្កានិងផ្លែច្រើន ជួយដល់ការដាក់គ្រាប់ពេញលេញ | រុក្ខជាតិក្រិនមានការបែកគុម្ពមានកំនត់ និងគ្រាប់ក្នុងមួយកួរមានកំនត់ការដាក់គ្រាប់មិនបានពេញលេញ។ ស្លឹកដែលចាស់ជាងគេតូចខ្លី ត្រង់ឡើងលើ ហើយស្លឹកមានពណ៌ខៀវលាយល្បឿង។ ***កំនត់ចំណាំ:*** ដំណាំទទួលអាស៊ូតច្រើនហួសបណ្តាលអោយខៀវខុសប្រក្រតី មិនធន់នឹងជំងឺ ងាយរលំដួល និងជាំទឹក។ |
| ផូស្វាត (P) | ជួយជំរុញដល់ការលូតលាស់នៃឫសធ្វើអោយដើមដងដំណាំរឹងមាំ ការលូតលាស់នៃផ្កានិងក្តិប ការបង្កើតគ្រាប់ និងធ្វើអោយដំណាំទុំស្រុះគ្នា | រុក្ខជាតិក្រិនមានការបែកគុម្ពមានកំនត់ ស្លឹកដែលចាស់ជាងគេតូចខ្លី ត្រង់ឡើងលើ និងមានពណ៌ខៀវចាស់កខ្វក់ ហើយស្លឹកខ្លះពណ៌ក្រហមទៅជាពណ៌ស្វាយ។ ដំណាំដាក់គ្រាប់មិនបានពេញលេញ។ |
| ប៉ូតាស (K) | បង្កើតអោយមានភាពធន់នឹងជំងឺ កត្តាចង្រៃ ដូចនេះរុក្ខជាតិមានសុខភាពល្អធន់នឹងការរលំដួល បង្កើនទំហំនិងទំងន់គ្រាប់ ជាតិស្ករ | ទំងន់គ្រាប់និងទំហំនៃគ្រាប់ថយចុះ ការដាក់គ្រាប់មិនបានពេញលេញ ស្លឹកដែលចាស់ជាងគេចាប់ផ្តើមពីចុងនៃស្លឹកប្រែពណ៌ពីលឿងទៅពណ៌ត្នោតស្រាល។ |

## ៤. ផលប្រយោជន៍នៃជីកំប៉ុស្ត:

* ជួយកែលំអរចនាសម្ព័ន្ធដីអោយមានជីជាតិកាន់តែប្រសើរឡើង
* ផ្តល់សារធាតុចិញ្ចឹម (ជីជាតិ)តាមតំរូវការរបស់ដំណាំ និងរុក្ខជាតិនានា
* ធ្វើអោយដីជប់ទឹកបានល្អលើសមុន៦ដង សំរាប់ផ្តល់អោយរុក្ខជាតិជាបណ្តើរៗ
* ជួយធ្វើអោយដីធូរមានខ្យល់ចេញញចូលបានល្អ និង ធ្វើអោយរុក្ខជាតិងាយស្រួលក្នុងការចាក់ឫសអាចស្រូបយកទឹក និងជីជាតិបានល្អ។
* ជួយសំរួលដល់ ប៉េហាស់របស់ដី អោយបានសមស្រប (កុំអោយជូរពេក និងកំបោរពេក)
* ជួយការពារដីកុំអោយហូរច្រោះដោយសារទឹកភ្លៀង

## ៥.សំភារៈសំរាប់ធ្វើជីកំប៉ុស្ត

### ៥.១.សំភារៈប្រើប្រាស់



* ទ្រុងធ្វើអំពីឈើ ឬឫស្សីសំរាប់ដាក់ជីកំប៉ុស្ត
* រទេះគោដឹកជញ្ជូន ឬ រទេះរុញ
* លួសសំណាញ់
* ចប ប៉ែល សម និងបង្គី
* កាំបិទ ផ្គាក់ ពូថៅ
* ឡាំងទឹក ឬ ធុងទឹក
* បង្គោលឫស្សី និងបង្គោលឈើ
* ខ្សែសំរាប់ចង

### ៥.២.សារធាតុសរីរាង្គ



* វត្ថុធាតុស្រស់ “បៃតង” មានជាតិអាសូតច្រើនៈ
  - ទន្ទ្រាងខែត្រ កំប្លោក ស្មោរ ស្មៅស្រស់។ល។
  - កាកសំណល់កសិកម្មស្រស់ៗមាន បន្លែ ពោត សណ្តែកនិងផ្លែឈើ ។ល។



* វត្ថុធាតុស្ងួត មានជាតិកាបោនច្រើនៈ
  - ស្លឹកឈើ ចំបើង កំប្លោក និងស្មៅស្ងួត។ល។
  - កំទេចអាចម៍រណា អង្កាម
  - សំបកសណ្តែកបាយ និងសណ្តែកដី



* លាមកសត្វគ្រប់ប្រភេទមាន គោ ក្របី ជ្រូក។ល។

## ៦-ការរៀបចំធ្វើជីកំប៉ុស្ត

ការធ្វើជីកំប៉ុស្តមានច្រើនរបៀបដូចតទៅ :

### ៦.១.របៀបធ្វើជីកំប៉ុស្តលើដីរាបស្មើ

* ជំហានទី១: ប្រមូលផ្តុំនៅវត្ថុដែលត្រូវធ្វើជីកំប៉ុស្ត យកចេញនូវវត្ថុ ណាដែលមិនរលួយដូចជា សំបកកំប៉ុង ថងប្លាស្ទីក ដែក អំបែងកែវ ។ល។



* ជំហានទី២: ជ្រើសរើសដីសំរាប់ធ្វើជីកំប៉ុស្ត ដីទួលរាបស្មើនៅក្បែរ ប្រភពទឹកដែលអាចដងស្រោច គំនរជីបានងាយស្រួល។



* ជំហានទី៣: បោះបង្គោលឬស្សីដោយកំណត់យកផ្ទៃដីទំហំ២ម ខ ៦ម សំរាប់គំនរកំប៉ុស្តរបស់អ្នក។



* <u>ជំហានទី៤</u>: គរស្លឹកឈើ ដើមពោត ចំបើង... ជាគំនរកំពស់ ១៤ស.ម រក្សាកំប៉ុស្តអោយមានខ្យល់ចេញចូលល្អ កុំហាប់ពេក។



* <u>ជំហានទី៥</u>: ក្រាលលាមកសត្វ ៥ស.ម ពីលើគំនរកំប៉ុស្តនោះ។



* <u>ជំហានទី៦</u>: ក្រាលផេះកំពស់ ២ស.ម ពីលើស្រទាប់លាមកសត្វនោះ។



* <u>ជំហានទី៧</u>: ធ្វើសារឡើងវិញដូចក្នុងជំហាន ទី៤,៥,៦ រហូតដល់កំប៉ុស្តមានកំពស់ ១ម ទៅ ១,៥ម



* <u>ជំហានទី៨</u>: ស្រោចទឹកពីលើគំនរកំប៉ុស្តដើម្បីរក្សាគំនរកំប៉ុស្តអោយសើម។



* <u>ជំហានទី៩</u>: បន្ទាប់ពី ៣អាទិត្យត្រូវប្រែត្រឡប់គំនរកំប៉ុស្តសារជាថ្មី ដោយយកស្រទាប់ខាងលើដាក់ទៅខាងក្រោម និងយកស្រទាប់ខាងក្រោមមកដាក់ខាងលើវិញ។



* ជំហានទី១០: រយះពេល ៥ អាទិត្យក្រោយមកត្រូវត្រលប់គំនរកំប៉ុស្តនេះម្តងទៀត ។ ត្រឡប់ស្រទាប់ទាំងនោះដាក់ក្នុងស្ថានភាពដើមវិញ និង ទុកអោយគំនរកំប៉ុស្តរំលួយក្នុងរយះពេល ៤អាទិត្យខាងមុខទៀត។



## កត្តា ៤យ៉ាងដែលនាំអោយការធ្វើកំប៉ុស្តទទួលបានជោគជ័យ:

◊ ធាតុសរីរាង្គ : ផលធៀបរវៀងកាបោន និងអាស៊ូត ២៥:១

◊ ខ្យល់ : ត្រូវមានខ្យល់ចេញចូលនៅក្នុងគំនរកំប៉ុស្តជានិច្ច

◊ សំណើម : សំណើមនៅក្នុងគំនរកំប៉ុស្តត្រូវការគ្រប់គ្រាន់ ៤០-៦០%

◊ សីតុណ្ហភាព : សីតុណ្ហភាពក្នុងគំនរដែលត្រឹមត្រូវល្អគឺ ៧០អង្សាសេ

## ៦.២.របៀបធ្វើជីកំប៉ុស្តក្នុងទ្រុង:

### ក-ការធ្វើជីកំប៉ុស្តក្នុងទ្រុងមាន ២ប្រភេទគឺ:

◊ ទ្រុងធ្វើអំពីឈើ ឬ ឫស្សី: យកបន្ទះឈើ ឬបន្ទាឫស្សីប៉ុន២ធ្នាប់ វាយជាផ្ទាំងឃ្លាតពីគ្នាមួយធ្នាប់ដៃ អោយបានទំហំ ១ម៉ែត្របួនជ្រុង ចំនួន៤ផ្ទាំង ដើម្បីផ្គុំភ្ជាប់បង្កើតបានជាទ្រុង។




◊ ទ្រុងធ្វើអំពីឈើ ទ្រុងធ្វើពីដែកលួសសំណាញ់:

ទិញលួសសំណាញ់ក្រឡា ៣ហ៊ុន ១ផ្ទាំងប្រវែង ៣ម៉ែត្រ ទទឹង១ម៉ែត្រ ដោយវាយឈើគាបតាម ទទឹងលួសសំណាញ់ និងមានទំពក់ក្រវិល សំរាប់ ផ្តក់ ពេលយើងលើកបញ្ឈរជារង្វង់មូល។



## ខ-វត្ថុធាតុផ្សំ:

◊ វត្ថុធាតុស្ងួតមាន ចំបើង ស្មៅស្ងួត សំបកសណ្តែក..........។ល។

◊ វត្ថុធាតុស្រស់មាន កំប្លោក ស្មៅ ទន្រ្ទានខែត្រ ស្លឹកឈើ.....។ល។

◊ លាមកសត្វ លាមកគោ ក្របី ជ្រូក មាន់............។ល។

## គ-ដំណើរការធ្វើជីកំប៉ុស្ត:

◊ បំផុសដីនៅត្រង់កន្លែងដាក់ទ្រុងកំប៉ុស្ត

◊ ផ្គុំបន្ទះឈើឬឫស្សីទាំង ៤ផ្ទាំងអោយកើតជាទ្រុងកំប៉ុស្តមួយ

◊ ដោតបង្គោលប៉ុនកំភួនដៃចំកណ្តាលទ្រុង

◊ រៀបបញ្ចូលគំនរកំប៉ុស្តតាមស្រទាប់នីមួយៗ

- វត្ថុធាតុស្ងួតចិញ្រ្ចាំអោយល្អិត កំពស់ ២៥ស.ម
- វត្ថុធាតុស្រស់ចិញ្រ្ចាំអោយល្អិត កំពស់ ១០ស.ម
- លាមកសត្វ កំពស់ ៥ស.ម

◊ ធ្វើដូចនេះទាល់តែពេញទ្រុង ហើយស្រោចទឹកអោយបានជោគល្មមពេលដាក់ធាតុផ្សំនីមួយៗ

◊ ដកបង្គោលដែលដោតចំកណ្តាលចេញ អោយខ្យល់ចេញចូលបង្កើតជាកំដៅ

◊ យកស្លឹកត្នោត កន្ទេលចាស់ៗ គ្របពីលើដើម្បីការពារភ្លៀង និងកំដៅថ្ងៃ

## ឃ-ការកាយត្រឡប់កំប៉ុស្ត

◊ ពេលរៀបចំគំនរកំប៉ុស្តបានរយះពេល ១០ថ្ងៃក្រោយមក ត្រូវកាយត្រឡប់វាដើម្បីអោយវាមានកំដៅ និងឆាប់រលួយ។

◊ បំផុសដីកន្លែងថ្មីនៅក្បែរទ្រុងកំប៉ុស្តចាស់

◊ ស្រាយចំណង ឬដោះទំពក់ទ្រុងចាស់ដើម្បីយកមកតំលើងនៅកន្លែងថ្មីនិងដោតបង្គោលចំកណ្តាលទ្រុងដូចមុន។

◊ ប្រើប៉ែល សម ចូកមួយស្រទាប់ម្តងៗយកមកដាក់ចូលក្នុងទ្រុងថ្មីតាមលំដាប់លំដោយតាមស្រទាប់នីមួយៗពីលើចុះក្រោម។

◊ រយះពេល ៣ថ្ងៃក្រោយពីការកាយត្រឡប់លើកទី១ ត្រូវចាប់ កាយត្រឡប់លើកទី២។ ការកាយត្រឡប់ត្រូវធ្វើក្នុងរយះពេល ៣ថ្ងៃម្តង រហូតដល់រយះពេល១ខែ ជីកំប៉ុស្តនិងអាចយកមកប្រើការបាន។

## ខ-ដំណោះស្រាយពីជីកំប៉ុស្ត

| បញ្ហា | មូលហេតុ | ដំណោះស្រាយ |
|---|---|---|
| -ជីកំប៉ុស្តធំក្លិនឧស្មន័ | -សំបូរជាតិអាស៊ូតច្រើនពេក | -បន្ថែមកំទេចអាចម៍រណា ឬវត្ថុធាតុស្ងួតផ្សេងៗ<br>-កាយត្រឡប់អោយបានញឹកញាប់ដើម្បីអោយ |
| -អាម៉ូញាក់ឆេះ | -ខ្វះអុកស៊ីហ្សែន | -ខ្យល់អុកស៊ីសែនចេញចូលបាន |
| -កំប៉ុស្តមិនឡើងកំដៅ | -អាស៊ូតមិនគ្រប់គ្រាន់<br>-សើមជ្រុលពេក<br>-ស្ងួតជ្រុលពេក<br>-ជាតិអាស៊ីតច្រើនជ្រុល | -បន្ថែមជីលាមកសត្វ<br>-បន្ថែមអាចម៍រណា<br>-បន្ថែមទឹកនៅពេលកាយ ត្រឡប់កំប៉ុស្ត<br>-បន្ថែមកំបោរនៅពេលកាយ ត្រឡប់ |

# XII-ដំណាំឈើហូបផ្លែ

ដំណាំឈើហូបផ្លែ គឺជាដំណាំមួយប្រភេទដែលផ្តល់ផ្លែជាចំណីអាហារសំរាប់មនុស្ស និង សត្វគ្រប់ប្រភេទ។ ក្រៅពីនេះ មនុស្សយើងអាចរកផលប្រយោជន៍ពីដំណាំឈើហូបផ្លែនេះដោយបេះយកផ្លែរបស់វាពីក្នុងព្រៃធម្មជាតិ ឬ ចំការឈើហូបផ្លែដែលបានដាំដើម្បីយកមកបរិភោគ និង រកប្រាក់ចំណូលសំរាប់គ្រួសារបានយូរអង្វែងទៀតផង។

## ១-ផលប្រយោជន៍នៃដំណាំឈើហូបផ្លែ

- ដំណាំឈើហូបផ្លែផ្តល់ផ្លែ ម្លប់ អុសដុត
- ផ្លែរបស់វាផ្តល់រស់ជាតិឆ្ងាញ់ និងនាំអោយយើងមានសុខភាពល្អ
- អាចរកប្រាក់ចំណូលបានច្រើន តាមតំរូវការទីផ្សារ
- ផ្តល់សោភណ៍ភាពស្រស់បំព្រង នៅជុំវិញផ្ទះ កសិដ្ឋាន។ល។

## ២-រដូវកាលនៃការដាំដុះ

- ដើមរដូវភ្លៀង គឺចាប់ពីខែ មិថុនា និងខែកក្កដា
- នៅចុងរដូវភ្លៀង គឺចាប់ពីខែ តុលា និងខែ វិច្ឆិកា

## ៣-ការជ្រើសរើសទីកន្លែងដាំ

- ដីមានជីជាតិ ដីខ្ពស់មិនលិចទឹក និងមានពន្លឺគ្រប់គ្រាន់
- កន្លែងមានប្រភពទឹកសំរាប់ស្រោចស្រពគ្រប់គ្រាន់រហូតដល់រដូវប្រាំង
- កន្លែងសមស្របទៅនឹងប្រភេទដំណាំដែលត្រូវដាំ
- ទីកន្លែងដែលនៅជិតផ្លូវអាចចេញចូលងាយស្រួលដល់ការដឹកជញ្ជូន

## ៤-ការរៀបចំដីសំរាប់ធ្វើចំការ

### ៤-១-ការរៀបចំប្លង់

ការរៀបចំប្លង់ចំការឈើហូបផ្លែ យើងត្រូវគិតគូរអោយបានច្បាស់លាស់អំពីទីតាំងសំរាប់ជីកស្រះរោងបណ្តុះកូនឈើ រោងជីកំប៉ុស្ត ប្រពន្ធ័ស្រោចស្រព ផ្លូវ និង ប្រពន្ធ័ដាំដុះ។ល។

## ៤.២.ការរៀបចំរបងការពារដំណាំ

ការធ្វើរបងអោយបានជិតល្អអាចការពារសត្វពាហនៈចូលមកបំផ្លិចបំផ្លាញដំណាំរបស់យើងបាន ។ របងអាចធ្វើអំពី បង្គោលឈើ ឬក៏បង្គោលស៊ីម៉ង់ដោយហ៊ុំពទ្ធ័លួសបន្លា ឬរបាំងជុំវិញរបងការពារទៅតាមលទ្ធភាពរបស់ម្ចាស់ចំការ ។

## ៤.៣.ការរៀបចំប្រព័ន្ធស្រោចស្រព

ការរៀបចំប្រព័ន្ធស្រោចស្រព គឺជាការងារមួយចាំបាច់ដើម្បីធានាដល់ការបញ្ចេញ បញ្ចូលទឹកសំរាប់ការស្រោចស្រពដំណាំអោយលូតលាស់បានល្អ ។ ការរៀបចំប្រព័ន្ធស្រោចស្រពនេះរួមមាន ប្រឡាយទឹក ស្រះ អណ្តូង ។ល។

## ៤.៤.ការរៀបចំប្រព័ន្ធដាំដុះ

### ក.ការរៀបចំរង

ត្រូវពិនិត្យមើលជាក់ស្តែងទៅតាមស្ថានភាពដី :

- **ដីលិចទឹក** : ត្រូវជីកជាប្រឡាយ ដីដែលបានមកពីប្រឡាយត្រូវផ្តុំអោយបានទៅជារងខ្ពស់ផុតពីទឹក ។
- **ដីមិនលិចទឹក**: យើងមិនបាច់ជីកប្រឡាយ ឬលើករងក៏បានដែរ អាស្រយ័ទៅលទ្ធភាពទុនរបស់ម្ចាស់។

**ខ.គំលាតដាំ:** វាអាស្រយ័ទៅតាមប្រភេទនៃដំណាំ ។

- សំរាប់ដំណាំ ស្វាយ ខ្នុរ ដូង គូលេន ធូរេន អាចមាន ចន្លោះគុម្ព និងចន្លោះជួរ:

  ៨ម x ៨ម x ៨ម

  ១០ម x ១០ម x ១០ម

- សំរាប់ដំណាំ ក្រូច ល្មុត ស្វាយចន្ទី អាចមាន ចន្លោះគុម្ព និងចន្លោះជួរ:

  ៥ម x ៥ម x ៥ម

  ៦ម x ៦ម x ៦ម

- សំរាប់ដំណាំ ចេក ល្ហុង ទៀប ត្របែក អាចមាន ចន្លោះគុម្ព និងចន្លោះជួរ:

  ៣ម x ៣ម x ៣ម

### គ.ការរៀបចំរណ្តៅ

មុននឹងធ្វើការដាំដុះត្រូវរៀបចំភ្ជួររាស់ដីអោយបានល្អជាមុនសិន បន្ទាប់មកត្រូវធ្វើការវាស់វែងចន្លោះគុម្ព និងចន្លោះជួរសំរាប់ជីករណ្តៅទៅតាមប្រភេទពូជដំណាំឈើហូបផ្លែដែលយើងត្រូវដាំ។ ទំហំរណ្តៅដែលត្រូវជីកមាន:

១ម x ១ម x ១ម

០,៧៥ម x ០,៧៥ម x ០,៧៥ម

០,៥០ម x ០,៥០ម x ០,៥០ម

- របៀបជីករណ្តៅ  ត្រូវជីកយកដីស្រទាប់លើជំរៅ  ៣០ស.ម  ដាក់មកមាត់រណ្តៅម្ខាង ហើយជីកយកដីស្រទាប់ក្រោមទៅដាក់នៅមាត់រណ្តៅម្ខាងទៀត។
- នៅបាតរណ្តៅត្រូវដាក់  ចំបើង  កន្ទ្រាងខែត្រ  កំរាស់  ២៥ស.ម
- ដាក់ដីដែលលាយជាមួយជីកំប៉ុស្ត  ឬលាមកសត្វ  ជីគីមី  កំរាស់  ១០ស.ម
- ពូនដីរណ្តៅអោយខ្ពស់ជាងដីធម្មតា  ពី  ២០  ទៅ  ៣០ស.ម




## ៥-ការជ្រើសរើសពូជ

- ពូជដែលមានគុណភាពល្អ  ដើមថ្លោសហើយរឹងមាំ
- អាចដុះលូតលាស់បាននៅតំបន់ដែលយើងចង់ដាំ
- ពូជដែលគ្មានជំងឺ  ធន់ទ្រាំនឹងសត្វល្អិតបំផ្លាញ
- ពូជដែលផ្តល់ទិន្នផលខ្ពស់
- ជាប្រភេទពូជពេញនិយមនៅទីផ្សារ

## ៦-របៀបដាំ

មុននឹងចាប់ផ្តើមដាំ  យើងយកកូនឈើហូបផ្លែដែលបានមកពីការបំបៅមែក  សាកមែក  ឬក៏បណ្តុះនៅក្នុងថង់ប្លាស្ទីក យកមកដាក់នៅក្នុងរណ្តៅដែលយើងបានត្រៀមជាស្រេច  ជំរៅ  ២០ស.ម  ។  បន្ទាប់មកយើងយកកូនកាំបិទមកវះថង់ប្លាស្ទីក រួចលើកកូនឈើដាក់ថ្នមៗចំកណ្តាលនៃរណ្តៅ  ដៃម្ខាងទប់កូនឈើអោយត្រង់  ដៃម្ខាងទៀតកាយដីលប់  រួចសង្កត់ដីជុំវិញកូន

ឈើនោះអោយណែនល្មម យកឬស្សីមកបោះអោយរាងបញ្ឈិតបន្តិច ហើយចង់ភ្ជាប់ទៅនិងកូនឈើដើម្បីការពារខ្យល់ ។ យកចំបើង ឬកន្ទ្រាងខែត្រមកគ្របក្បែរគល់ជុំវិញ ហើយស្រោចទឹកអោយបានជោគជាំជាការស្រេច ។

**ចំណាំៈ** - ចំពោះកូនឈើដែលបានមកពីការបំបៅមែក ហាមលប់ដីលិចមុខដំណរុំស្គត់ ព្រោះអាចអោយកូនឈើងាប់

- ហាមយកសំរាមមកគ្របផ្ទាល់និងគល់ដែលអាចធ្វើអោយមានជំងឺ កំដៅនាំអោយកូនឈើខូច ឬងាប់បាន

## ៧-ការគ្រប់គ្រងចំការ

### ក-ការស្រោចស្រព:

ចំពោះកូនឈើដែលទើបដាំរួច ត្រូវស្រោចទឹកអោយបានទៀងទាត់ជារៀងរាល់ថ្ងៃ ។ ឈើហូបផ្លែដែលត្រូវការទឹកច្រើនសំរាប់ស្រោចស្រពគឺនៅដំណាក់កាលចេញផ្កា និងផ្លែ ដោយសារកំរិតនៃការដកដង្ហើមរបស់វាខ្ពស់ នៅក្នុងដំណាក់កាលនេះ។ កង្វះខាតទឹកនាំអោយការធ្វើរស្មីសំយោគរបស់វានិងត្រូវផ្អាក ដែលអាចបណ្តាលអោយផ្កា និងផ្លែនឹងត្រូវជ្រុះ ។ ដូច្នេះនៅដំណាក់កាលចេញផ្កា និងផ្លែដំបូង ការស្រោចស្រពត្រូវអោយបានគ្រប់គ្រាន់ ។

### ខ-ការកំចាត់ស្មៅ

ត្រូវកំចាត់ស្មៅអោយបានញឹកញាប់ដើម្បីកុំអោយវារំខាន និង ដណ្តើមជីពីដំណាំ។ ម្យ៉ាងទៀតស្មៅក៏ជាជំរករបស់សត្វល្អិត និង ជំងឺដែរ ។ គេអាចកំចាត់ស្មៅដោយដកនិងដៃ ប្រើចប កាប់នឹងកាំបិទ ភ្ជួរលុប ដាំដំណាំចំរុះ ដាំដំណាំគ្របដី ឬគ្របដីជុំវិញក្បែរគល់ដំណាំជាមួយចំបើង ស្មៅដែលជំរះឬ ស្លឹកកន្ទ្រាងខែត្រ ។ វិធីសាស្ត្រគ្របគល់ដំណាំនេះមិនត្រឹមតែអាចកំចាត់ស្មៅប៉ុណ្ណោះទេ វាក៏អាចរក្សាសំណើមផងដែរ។

### គ-ការដាក់ជី

ជីមានសារះសំខាន់ណាស់ចំពោះដំណាំទាំងការលូតលាស់ ផ្កា និងផ្លែ ។ ការដាក់ជីធម្មជាតិ និង ជីគីមីលើដំណាំឈើហូបផ្លែ វាអាស្រយ៍ទៅតាមប្រភេទដី អាយុកាលនៃដំណាំឈើហូបផ្លែ និងជីជាតិដី ។ កំរិតជីដែលគួរប្រើសំរាប់ដំណាំឈើហូបផ្លែមាននៅក្នុងតារាងដូចខាងក្រោម:

| ការដាក់ជីទៅតាមអាយុកាលនៃដំណាំឈើហូបផ្លែ | | | |
|---|---|---|---|
| ឆ្នាំ | ផូស្វ័រ០.៣ kg (០.២០.០) | ប៉ូតាស្យូម០.៣ kg (០.០.៦០) | នីត្រូសែន ០.៣ kg (៤៦.០.០) |
| ១ | គីមី ០,១១kg + កំប៉ុស្ត ១៣ kg | គីមី ០,១១kg + កំប៉ុស្ត ១៣ kg | គីមី ០,១១kg + កំប៉ុស្ត ១៣ kg |
| ២ | គីមី ០,៣៣kg + កំប៉ុស្ត ១៣ kg | គីមី ០,៣៣kg + កំប៉ុស្ត ១៣ kg | គីមី ០,៣៣kg + កំប៉ុស្ត ១៣ kg |
| ៣ | គីមី ០,៥kg + កំប៉ុស្ត ១៣ kg | គីមី ០,៥kg + កំប៉ុស្ត ១៣ kg | គីមី ០,៥kg + កំប៉ុស្ត ១៣ kg |
| ៤ | គីមី ០,៦៧kg + កំប៉ុស្ត ៣០ kg | គីមី ០,៦៧kg + កំប៉ុស្ត ៣០ kg | គីមី ០,៦៧kg + កំប៉ុស្ត ៣០ kg |
| ៥ | គីមី ០,៨៣kg + កំប៉ុស ៣០ kg | គីម ០,៨៣kg + កំប៉ុស្ត ៣០ kg | គីមី ០,៨៣kg + កំប៉ុស្ត ៣០ kg |
| ៦ | គីមី ១,០kg + កំប៉ុស្ត ៣០kg | គីមី ១,០kg + កំប៉ុស្ត ៣០ kg | គីមី ១,០kg + កំប៉ុស្ត ៣០ kg |

| | | | |
|---|---|---|---|
| ៧ | គីម ១,១៧kg + កំប៉ុស្តិ៣០ kg | គីមី១,១៧kg + កំប៉ុស្ត ៣០ kg | គីមី១,១៧kg + កំប៉ុស្ត ៣០ kg |
| ៨ | គីមី ១,៣៣kg + កំប៉ុស្ត៣០ kg | គីមី១,៣៣kg + កំប៉ុស្ត ៣០ kg | គីមី១,៣៣kg + កំប៉ុស្ត ៣០ kg |
| ៩ | គីមី ១,៥ kg + កំប៉ុស្ត ៣០ kg | គីមី ១,៥ kg + កំប៉ុស្ត ៣០ kg | គីមី ១,៥ kg + កំប៉ុស្ត ៣០ kg |
| ១០ | គីមី១,៦៧ kg + កំប៉ុស្ត ៣០ kg | គីមី ១,៦៧kg + កំប៉ុស្ត ៣០ kg | គីមី ១,៦៧ kg + កំប៉ុស្ត ៣០ kg |

- ចំពោះកូនឈើហូបផ្លែដែលមានអាយុពី ១ទៅ៣ឆ្នាំ ពេលវេលាដាក់ជីគីមាន ៣លើក:
  - ពេលដើមរដូវភ្លៀង
  - ក្រោយរដូវភ្លៀង
  - ក្រោយរដូវប្រមូលផល
- ចំពោះឈើហូបផ្លែដែលបានផ្តល់ផ្លែហើយ មានអាយុពី ៤ទៅ១០ឆ្នាំ ពេលវេលាដាក់ជីមាន ៣លើក:
  - ក្រោយពេលប្រមូលផល
  - ដំណាក់កាលចេញផ្កា
  - ដំណាក់កាលផ្លែ

របៀបនៃការដាក់ជី ដំបូងត្រូវកាប់ដីឆ្វៀលជុំវិញត្រឹមចុងស្លឹកដំណាំឈើហូបផ្លែជំរៅ ២០ស.ម បន្ទាប់មកដាក់ជីទៅតាមកំរិតដែលបានកំនត់នៅក្នុងតារាងខាងលើ តាមពេលវេលា និងអាយុកាលនៃដំណាំឈើហូបផ្លែ ។ ពេលដាក់ជីរួចហើយត្រូវលុបដីអោយជិត ហើយយកចំបើងឬកន្ទ្រាងខែត្រមកគ្របជុំវិញក្បែរគល់រួចស្រោចទឹកអោយបានជោគ ។



### ឃ. ការកាត់តែងមែក

ការកាត់តែងមែកមានឥទ្ធិពលយ៉ាងខ្លាំងលើការលូតលាស់ ការចេញផ្កា និងផ្លែ ។

ហេតុអ្វីការកាត់តែងមែកមានប្រយោជន៍ :

ការកាត់តែងមែកគឺយកចេញនូវមែកដែលចង្អៀត និងគ្មានសុខភាពល្អ ហើយគួរតែធ្វើនៅពេលកូនឈើនៅតូច។

- ការកាត់តែងមែកធ្វើអោយរឹងមាំដល់ទ្រង់ទ្រាយរបស់ដើមឈើ
- ដើមឈើត្រូវការទ្រង់ទ្រាយដែលល្អដើម្បីងាយស្រួលដល់ការប្រមូលផល ការបាញ់ថ្នាំនិងការងារផ្សេងទៀត
- ការកាត់តែងមែកជំរុញអោយមានផ្លែស្មើគ្នាគ្រប់មែក
- ការកាត់តែងមែកជំរុញអោយមានផ្លែច្រើន ផ្លែធំ និង រស់ជាតិឆ្ងាញ់

ជាទូទៅ គោលបំណងនៃការកាត់តែងមែកគឺដើម្បីយកចេញមែកដែលងាប់ មែកដែលមានជំងឺ មែកដែលខូចនិងមែកដែលគ្មានប្រយោជន៍ (មែកគងលើគ្នា មែកអំពង មែកកកិតគ្នា មែកតូច ។ល។)។




## ៨. ការពង្រីកពូជ

ការពង្រីកពូជមានលក្ខណះច្រើនយ៉ាងតាមរយះ ការបណ្តុះកូន ការសាក ការបំពៅ របៀបតកូន របៀប តត្រួយ របៀបភ្ជាប់ភ្នែក ។ល។

### ក. វិធីសាក

ត្រូវជ្រើសរើសយកមែកតូចល្មម (មិនត្រូវរើសយកមែកអំពងទេ) បន្ទាប់មកកាត់ពីរកន្លែងមិនចំថ្នាំងឃ្លាតពីគ្នាប្រវែង ២,៥ស.ម រួចយកសំបកចេញ កោសយកជ័រអិលចេញអោយអស់ដោយកោសពីលើចុះមកក្រោម បន្ទាប់មកទៀតយកអកមួន

មកលាបផ្នែកខាងលើ រួចហើយយកស្លឹកចេកមករុំកន្លែងលាក់ដើម្បីការពារកុំអោយត្រូវកំដៅថ្ងៃខ្លាំងពេក ហើយទុករយៈពេល ៧ថ្ងៃ ស្នាមលាក់នឹងផ្តើមចេញដុំពក រួចយើងយកថង់ស្រកីដូងដែលបានត្រៀមជាស្រេចមកពុះ ហើយហែកបញ្ចូលទៅកន្លែងលាក់ ដោយចងចុងខាងលើអោយជាប់ រួចចងចុងខាងក្រោម និងចងកណ្តាល អោយតឹងណែនល្អ ។ រយៈពេល ១ទៅ២ខែ ឫសចាប់ផ្តើមដុះ យើងទុកអោយឫសមានសភាពពណ៌ត្នោតទើប យើងកាត់យកមកផ្សាំ។

### ខ-វិធីបំបៅ

ក្រោយពេលដំណាំឈើហូបផ្លែត្រូវបានដាំចាប់ពី ២-៣ ឆ្នាំឡើងទៅ យើងអាចពង្រីកពូជតាមរយៈការបំបៅ មែកដោយគ្រាន់តែដកយកកូនដែលបានបណ្តុះរួច មានទំហំដើមប៉ុនចង្កឹះទៅលាងទឹកអោយស្អាតយកមកកាត់ឫសចេញ អោយបានល្អ ទុកតែឫសកែវអោយនៅប្រវែង ៥-៧,៥ស.ម។ យកអរកមក ( Seradix) មកលាយទឹកធម្មតាអោយខាប់ហើយត្រាំរយៈពេលពី ៥-១៥នាទី រួចទុកក្នុងម្លប់អោយស្ងួត ទើបយើងដាក់ចូលទៅក្នុងថង់ស្រកីដូង ទំហំ ១០ស.មX១៥ស.ម ដោយញាត់អោយណែនល្អ រួចចងផ្នែកខាងមាត់ថង់អោយជាប់ការពារកុំអោយទឹកជ្រាបចូលបាន បើមិនស្ងួវណែនទេចងចំពាក់កណ្តាលថង់ស្រកីទៀត ។ ត្រូវចិតដើមគល់ (rootstock) រាងបញ្ឆិត ប្រវែង ៤-៥ ស.ម ហើយជ្រើសរើសមែកពូជល្អប៉ុនម្រាមដៃរួចចិតសំបកពីខាងគល់ទៅខាងចុងបញ្ឆិតចូលទៅដល់សាច់ឈើ ប្រវែង ៤-៥ស.ម យកសំបកចេញដោយទុកអណ្តាតបន្តិច ។ នាំយកដើមគល់ដែលបានរៀបចំទៅស៊ៀតក្នុងមុខដំណាប់របស់មែកពូជអោយសាច់សំបកត្រូវគ្នាល្អម បើមែកធំជាងដើមគល់ត្រូវដាក់អោយសាច់សំបកត្រូវគ្នាតែ ម្ខាងបានហើយ រួចរុំស្កុតពីលើចុះមកក្រោមខាងគល់មែកអោយណែនទុកជាការស្រេច ។ រយៈពេល ១ខែ ទៅ ១ខែកន្លះ យើងអាចកាត់យកមកផ្សាំបានហើយ។ មុននឹងកាត់ផ្សាំត្រូវលាក់ក្រោមមុខដំណាប់បំបៅប្រហែល ២ស.ម ទុករយៈពេល ៧ថ្ងៃ ទើបកាត់យកទៅផ្សាំ ។ ក្រោយពេលកាត់ ត្រូវយកទៅទំលាក់ក្នុងទឹក កន្លះម៉ោង ទៅ ១ម៉ោង ទើបយកទៅដាក់ក្នុងថង់ផ្សាំ ទុកក្នុងម្លប់រយៈពេល ២អាទិត្យ រួចបញ្ចេញវាមកកន្លាល។



## គ. របៀបតត្រួយ

គេច្រើនដាំណាំឈើហូបផ្លែពូជក្នុងស្រុកដែលផ្លែមិនសូវឆ្ងាញ់ មិនសូវមានតំលៃ ប៉ុន្តែវាមានការធន់ទ្រាំទៅនិងអាកាសធាតុរាំងស្ងួត ទឹកជំនន់ និងជំងឺ ។ល។ វិធីសាស្ត្រនេះគេច្រើនអនុវត្តនៅដើមរដូវភ្លៀង និង ចុងរដូវភ្លៀង ។ ជាដំបូងត្រូវយកត្រួយពូជល្អ (ជិតចេញពន្លក)មាន ប្រវែង ១០-១៥ស.ម ហើយចិតបញ្ឆិតប្រវែង ៤ស.ម ។ បន្ទាប់មកចិតសំបកដើមពីខាងចុងចុះទៅខាងក្រោមបញ្ឆិតចូលទៅដល់សាច់ឈើប្រវែង ៤ស.ម (ដើមដែលត្រូវស៊ៀតត្រួយពូជ) យកសំបកចេញដោយទុកអណ្តាតបន្តិច ។ នាំយកត្រួយដែលបានរៀបចំជាស្រេចទៅស៊ៀតក្នុងមុខដំណាប់របស់ដើមអោយសាច់សំបកត្រូវគ្នាល្មម បើដើមធំជាងត្រួយពូជត្រូវដាក់អោយសាច់សំបកត្រូវគ្នាតែម្ខាងបានហើយ រួចរុំស្គត់ពីក្រោមឡើងទៅលើរហូតលិចបាត់ចុងត្រួយពូជដើម្បីរក្សាសំណើម ។ រយះពេល ៣ ទៅ ៤ អាទិត្យ បើត្រួយនៅស្រស់ល្អ យើងត្រូវស្រាយស្គត់ចេញពីចុងត្រួយបន្តិចដើម្បីអោយពន្លកត្រួយដុះចេញមកបាន ។ បន្ទាប់មកត្រូវយកចុងកាំបិទឆូតស្គត់រុំខាងក្រោមបន្តិចការពារកុំអោយទឹកដក់អាចរលួយចុងត្រួយ ។ នៅពេលចុងត្រួយពូជល្អដុះចេញសន្លឹកហើយ យើងត្រូវកាត់មែក ឬ ដើមចាស់ចោលចេញ ធ្វើយ៉ាងណាអោយត្រួយពូជដុះបានល្អ ។




## ឃ. របៀបពុះបញ្ចូលត្រួយ

យើងត្រូវកាត់មែក ឬ ដើមពូជមិនល្អចេញ រួចពុះចំពីលើប្រវែង ៣-៤ស.ម ហើយយកត្រួយពូជល្អមកចិតបញ្ឆិតសង្ខាង ៣-៤ស.ម រួចសិកចូលទៅក្នុងមែកឬដើមដែលយើងបានពុះនោះ បើមែកឬដើមធំជាងត្រូវព្យាយាមអោយសំបកត្រូវគ្នាតែម្ខាងបានហើយ រួចរុំស្គត់ពីក្រោមឡើងលើអោយណែនត្រង់មុខតំណពុះ ។ ចំពោះចុងពូជល្អត្រូវយកថង់ប្លាស្ទីកមកច្រកពីលើរួចចងអោយជាប់ ។ រយះពេល ៣-៤អាទិត្យ យើងស្រាយថង់ប្លាស្ទីកចេញ បើត្រួយនៅស្រស់បានសេចក្តីថា វាជាប់មុខតំណហើយ រវាង ៥ អាទិត្យ ត្រួយចាប់ផ្តើមដុះចេញមក ។ រយះពេល ៤-៥ខែ ទើបរុះស្គត់រុំនោះចេញ ។



## ខ. <u>របៀបភ្ជាប់ភ្នែក</u>

ដំបូងត្រូវរះដើមពីលើចុះមកក្រោមតាមបណ្តោយនៃដើមប្រវែង ២-៣ ស.ម ហើយព្យាយាមឆ្កឹះសំបកចេញ រួចត្រូវបិទទៅវិញជាបន្ទាន់កុំអោយវាស្ងួតមុខ ។ ចិតសំបកភ្នែកពីមែកដែលបានត្រៀមទុកជាស្រេច ប្រវែង ២-៣ស.ម បកសាច់ឈើពីសំបកភ្នែកចេញដោយមិនអោយសំបកភ្នែកជាំឬប្រឡាក់ ព្រោះអាចនាំអោយមិនជាប់ផ្គាបាន ។ បន្ទាប់មក យើងបង្អើបសំបកដើមតមកកាត់ចេញ ២/៣ រួចយកភ្នែកពូជល្អទំហំតូចជាងបន្តិចមកស៊ៀតក្នុងស្នាមបង្អើប ទើបសង្កត់អោយសាច់សំបកជិតផ្គាបានល្អ ទើបរុំស្កត់ពីក្រោមឡើងទៅលើអោយជិតទាំងអស់ ។ ត្រូវគ្របការពារពន្លឺថ្ងៃកន្លែងដែលភ្ជាប់ភ្នែកនោះ ។

រយៈពេល ៣-៤ អាទិត្យ បើពិនិត្យឃើញថាភ្នែកនៅមានពណ៌បៃតង់ស្រស់ យើងសន្មត់ថាវាជាប់ផ្គាហើយ យើងត្រូវឆ្កឹះស្កត់ត្រង់កន្លែងភ្នែកបន្តិចដើម្បីអោយពន្លកត្រួយដុះចេញមកបាន ។ រយៈពេល ៥-៦អាទិត្យ ត្រួយដុះលូតលាស់ល្អ ហើយត្រូវកាត់មែក ឬ ដើមចាស់នោះចោលចេញ។



## XIII-វិធីសាស្ត្រក្នុងការកំចាត់កន្លាចក្រៃលើដំណាំ

ជាទូទៅពីមួយឆ្នាំទៅមួយឆ្នាំ ការដាំដុះតែងតែជួបប្រទះនិងការបំផ្លាញពីសត្វល្អិតចង្រៃ ហើយការរាតត្បាតចេះតែកើនឡើងជាលំដាប់។ ដូច្នេះដើម្បីការពារសត្វល្អិតចង្រៃទាំងនេះ គេអាចប្រើមធ្យោបាយទប់ទល់តាមវិធីសាស្ត្រមួយចំនួនដូចខាងក្រោមៈ

### ១-ការកំចាត់ដោយប្រើអន្ទាក់ភ្លើង

ប្រើអន្ទាក់ភ្លើងពណ៌ខៀវដើម្បីទាក់ទាញ និងកំចាត់ មេអំបៅដង្កូវចោះផ្លែ ពពួកមមាចត្នោត និងសត្វល្អិតចង្រៃផ្សេងទៀត...។ល។

### ២-ការកំចាត់ដោយចាប់និងដៃ

ការកំចាត់ដោយចាប់និងដៃអាចមានប្រសិទ្ធិភាពតែនៅលើផ្ទៃដីតូច និងចំពោះប្រភេទសត្វល្អិតដែលងាយស្រួលក្នុងការចាប់ដូចជាៈ ដង្កូវយោលទោង ដង្កូវស្រាវខៀវ ដង្កូវបាក់ខ្នង ដង្កូវកាត់ដើម.....។ល។ ការចាប់ដោយដៃពុំអាចចាប់អស់ទេគឺគ្រាន់តែបន្ថយចំនួនសត្វល្អិតបានមួយចំនួនតែប៉ុណ្ណោះ។

### ៣-ការកំចាត់តាមរបៀបដាំដុះ

ត្រូវភ្ជួរហាលដី កប់ដើមចាស់ចោល កំចាត់កាកសំណល់ក្រោយពេលប្រមូលផលរួច បំបាត់ជំរកសត្វល្អិត ដាំដុះអោយបានសមស្របទៅតាមរដូវកាលក៏ជាកត្តានៃការកាត់បន្ថយការស៊ីបំផ្លាញរបស់សត្វល្អិតដែរ ។ ម្យ៉ាងទៀតការជ្រើសរើសពូជដែលធន់ទ្រាំ និងសត្វល្អិតឬការផ្លាស់ប្តូរមុខដំណាំក៏អាចបន្ថយការរាតត្បាតពីសត្វល្អិតចង្រៃដែរ។

### ៤-ការកំចាត់តាមរបៀបជីវសាស្ត្រ

នៅប្រទេសកសិកម្មជឿនលឿន គេកំចាត់សត្វល្អិតចង្រៃដោយប្រើរបៀបជីវសាស្ត្រ។ ការកំចាត់តាមរបៀបនេះមិនធ្វើអោយប៉ះពាល់ដល់សុខភាព មនុស្ស សត្វ។ សត្វមួយចំនួនមានប្រយោជន៏ណាស់ហើយអាចជួយបំផ្លាញសត្វល្អិតចង្រៃទៀតផងដូចជាៈ ចាប កង្កែប បង្កួយ ពស់ សត្វរំពា ប៉ារ៉ាស៊ីត.....។ល។

### ៥- ការកំចាត់ដោយប្រើថ្នាំពុល

### ៥-១-ថ្នាំពុលផ្សំពីរុក្ខជាតិ

### ហេតុអ្វីបានជាត្រូវប្រើថ្នាំពុលផ្សំពីរុក្ខជាតិ ?

ការប្រើប្រាស់ថ្នាំពុលកសិកម្មក្នុងកំរិតខ្ពស់ និងរយះពេលយូរអង្វែងធ្វើអោយមានឥទ្ធិពលមិនល្អទៅលើសុខភាពរបស់កសិករដែលជាអ្នកផលិត និងទៅលើអ្នកបរិភោគផលិតផលទាំងនោះ។មិនតែប៉ុណ្ណោះថ្នាំពុលទាំងនោះបានធ្វើអោយមានភាពកខ្វក់ និងអន្តរាយដល់បរិយាកាសនៅជុំវិញ ជាពិសេសដល់សត្វមានប្រយោជន៏“សត្រូវធម្មជាតិរបស់សត្វល្អិត

ចង្រៃ”ដូចជា សត្វស្លាប បង្គួយ ពួកកង្កែប ពីងពាង ឱម៉ាល់ ត្រី......។ល។ ក្រៅពីនោះជីជាតិនៅក្នុងដីក៏ថយចុះ ឯទំរង់របស់ដីក៏កាន់តែអន់ទៅ ហើយសារធាតុពុលត្រូវទឹកនិងខ្យល់នាំយកទៅផង។ ដោយហេតុនេះហើយការប្រើប្រាស់ថ្នាំពុលដំបូង គឺវាគ្រោះថ្នាក់ដល់កសិករ និងសត្វមានប្រយោជន៏ បន្ទាប់មកជាតិពុលបានធ្វើអោយកខ្វក់ដល់ផលិតផល ដី ទឹក និងខ្យល់ទៀតផង។

ថ្នាំពុលផ្សំពីរុក្ខជាតិគឺជាជំរើសមួយដែលមានសុវត្ថិភាព និងមានតំលៃថោកបំផុត ហើយអាចរកផ្សំបាននៅក្នុងមូលដ្ឋានរបស់យើង ។ ស្លឹក សំបក គ្រាប់ និងដើមរុក្ខជាតិមួយចំនួនអាចមានជាតិពុលដែលមានប្រសិទ្ធិភាពក្នុងការបណ្តេញ និងកំចាត់កត្តាចង្រៃខុសៗគ្នា។ នៅពេលដែលរៀបចំថ្នាំពុលផ្សំពីរុក្ខជាតិ ជានិច្ចកាលត្រូវហាលពួកវានៅក្នុងម្លប់ ព្រោះពន្លឺថ្ងៃអាចធ្វើអោយខូចដល់ធាតុសកម្មរបស់រុក្ខជាតិទាំងនោះបាន។ ច្រោះ ឬត្រងល្បាយថ្នាំដែលត្រាំនោះជាមួយនិងក្រណាត់ស្បៃ ដើម្បីយកកាកថ្នាំពុលផ្សំពីរុក្ខជាតិចោល។ បន្ថែមទឹកសាប៊ូដុំបន្តិចនិងជួយអោយទឹកថ្នាំមានជាតិស្អិតទៅ និងរុក្ខជាតិ។ ចំពោះលទ្ធផលនៃការប្រើប្រាស់ថ្នាំផ្សំពីរុក្ខជាតិកន្លងមកបានបង្ហាញអោយឃើញថាល្អដូចថ្នាំពុលកសិកម្មដែរ។ ម្យ៉ាងទៀតថ្នាំរុក្ខជាតិទាំងនេះពុំបានធ្វើអោយអន្តរាយដល់សុខភាពកសិករ អ្នកបរិភោគផលិតផល សត្រូវធម្មជាតិរបស់សត្វល្អិតចង្រៃ និងបរិស្ថានឡើយ។ ធម្មជាតិបានផ្តល់នូវរុក្ខជាតិជាច្រើនប្រភេទដែលមានសារធាតុគីមីអាចផលិតជាថ្នាំពុលផ្សំពីរុក្ខជាតិសំរាប់ការពារ និងកំចាត់សត្វល្អិតចង្រៃលើដំណាំ។ រុក្ខជាតិទាំងនោះមាននៅក្នុងតារាងខាងក្រោយ។

# រុក្ខជាតិអាចផ្សំជាថ្នាំកំចាត់សត្វល្អិត

%%%%%%%%%%%%%

| លរ | រុក្ខជាតិ | | វិធីផ្សំ | វិធីប្រើ | ប្រភេទសត្វល្អិត | ផ្សេងៗ |
|---|---|---|---|---|---|---|
| | ឈ្មោះខ្មែរ | ឈ្មោះ វិទ្យាសាស្ត្រ | | | | |
| ១ | រមៀត | Cucurma domestica | ១- ក្នុងឃ្លាំង ឬជង្រុកស្រូវ គេលាយម្សៅ រមៀត ក្នុងកំរិត ២ ភាគរយ ។<br>២- គេយកម្សៅរមៀត 0,៥ គក្រ ទៅត្រាំក្នុងទឹក ២ លីត្រ ចំនួន ១យប់ លុះព្រឹកឡើងច្រោះដោយស្បៃ ។ យកទឹករមៀត ១លីត្រ ទៅលាយជាមួយទឹក ១0 លីត្រ ។ | ទឹកថ្នាំនេះសំរាប់បាញ់លើច្បារបន្លែ ទំហំ ៥ ម៉ែត្របួនជ្រុង ។ | - ស្រមោច សត្វល្អិតកាត់ខោអាវ ខ្នូតគ្រាប់ធុញ្ញជាតិ ពួកស៊ីរូងគ្រាប់<br>- សំរាប់បង្ការដង្កូវឃោលទោង ដង្កូវហ្វូង ដង្កូវបំពង់កាត់ស្លឹក | |
| ២ | ស្ដៅ | Azedarachta indica | ១- ស្លឹកស្ដៅ៤គក្រ មើមរំដេង ២គក្រ ស្លឹកគ្រៃស្រស់២គក្រ បុកចូលគ្នាអោយម៉ត់ រួចត្រាំក្នុងទឹក ២0-២៥លីត្រ រយះពេល១-២ យប់ ។ ទឹកថ្នាំត្រង់រួចនេះ ១លីត្រ គេយកទៅលាយទឹក២0លីត្រទៀត ទើបយកទៅបាញ់ ។ | លើកទី១:បាញ់នៅពេលស្រូវអាយុ បាន ១0-១៥ថ្ងៃ<br>លើកទី២: បាញ់រៀងរាល់១0 ទៅ ១៥ថ្ងៃ លុះត្រាដល់ពេលស្រូវផើម<br>ក្នុងករណីដែលមានសត្វល្អិតបំផ្លាញច្រើន ត្រូវបាញ់ថ្នាំ ៣ទៅ៤ ថ្ងៃ ជាបន្តបន្ទាប់គ្នា ។ | ដង្កូវរយឬ ដង្កូវហ្វូង ដង្កូវមូលស្លឹក ដង្កូវឃោលទោង ដង្កូវបំពង់ ដង្កូវកាត់ស្លឹក មមាចត្នោត | គេអាចដាក់សាប៊ូដុំបន្តិចដើម្បីអោយមានប្រសិទ្ធភាពរិតតែខ្លាំង ។ ក្រៅពី ប្រើលើដំណាំស្រូវគេអាចប្រើលើដំណាំឈើហូបផ្លែ ប្រកបដោយជោគជយ័ ។ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | **២- ទឹកស្លឹកស្តៅ:** យកស្លឹកស្តៅ៥ គក្រ ដាក់ក្នុងទឹក ៣០លីត្រ  រួចដាំអោយពុះរយះពេលកន្លះម៉ោង ហើយទុក ១យប់អោយត្រជាក់។<br>**៣-ទឹកគ្រាប់ស្តៅ:** បុកគ្រាប់ស្តៅ ២គក្រ រួចយកទៅត្រាំក្នុងទឹកចំណុះពី ១៦ទៅ២០លីត្រ រយះពេល ១យប់ ឬ២យប់ ទើបត្រង។ ទឹកថ្នាំត្រងរួចនេះ យកទៅលាយជាមួយទឹកស្មើភាគគ្នា។<br>**៤- ម្សៅគ្រាប់ស្តៅ:**បុកគ្រាប់ស្តៅអោយម៉ត់<br><br><br><br><br>**៥-ស្តៅក្រៀមៈ**<br><br>**៦**-ស្តៅ( ស្លឹក ឬ គ្រាប់ក៏បាន)២ កញ្ជើ-ស្លាក់( ស្លឹក ឬគ្រាប់ក៏បាន) ១កញ្ជើ -ជន្លាត់ដៃ៣គក្រ -គ្រាប់ស្លែង ៣គក្រ ត្រាំក្នុងទឹក១ពាង ( ១២អំរែក) ទុករយះពេល ១៥ ទៅ ៣០ថ្ងៃ ទើបយកមកប្រើបាន។ | - ទឹកថ្នាំ៣០លីត្រសំរាប់បាញ់លើផ្ទៃដីទំហំ៣០ម x ២០ម<br><br>-គេបាញ់ទឹកថ្នាំនេះនៅរៀងរាល់ ៧ថ្ងៃ ឬនៅពេលមានសត្វល្អិតច្រើន<br><br>-គេបាចម្សៅនេះពី ៣៦-៥០គក្រ ក្នុងដី ១ហត ដោយចែកជាបីលើក<br>**លើកទី១:** ពេលរៀបចំដី<br>**លើកទី២:** ១០-១៤ថ្ងៃ ក្រោយពង្រោះ<br>**លើកទី៣:** មុនពេលស្រូវផើម<br>- បាចក្នុងកំរិត ១ ៨០០ គក្រ ក្នុង ១ហត<br>- យកទឹកថ្នាំនេះ ១លីត្រ លាយជាមួយទឹកធម្មតា ១៨លីត្រ ទើបយកទៅបាញ់លើដំណាំ។ | មមាចត្នោត មមាចខៀវ ស្រឹង  ទ្រីប ដង្កូវស៊ីស្លឹកពណ៏បៃតង  ដង្កូវមូរស្លឹក ដង្កូវស៊ីរូងដើម ដង្កូវផ្លែឈើ<br><br><br><br><br><br>- អាចបន្ថយយ៉ាងច្រើននូវការរលាកឬសប៉េងប៉ោះ<br>- វាអាចកំចាត់សត្វល្អិត ដូចជា ដង្កូវកូនជ្រូក  ដង្កូវហ្វូង  ដង្កូវដី និង ត្រចៀកគួរ  ។ | គេបាញ់ទឹកថ្នាំនេះ បានតែនៅពេលមុនស្រូវផ្កា។ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | ក្បៀស | Derris elliptica | ១-ឫសក្បៀសបុកអោយម៉ត់ជាម្សៅ ១គក្រ លាយទឹក ១០០លីត្រ នឹងសាប៊ូកន្លះ គក្រ<br>២-ម្សៅឫសក្បៀស ២គក្រកន្លះ លាយក្នុងទឹកចំនួន ៤០០លីត្រ<br>៣- កំទេចឫសក្បៀស | -បាញ់ទឹកថ្នាំនេះនៅពេលមានសត្វល្អិតច្រើន ឬ រៀងរាល់៧ថ្ងៃម្តង<br>-<br>សំរាប់កំចាត់ដង្កូវស្លែក្តោបគេ បាចកំទេចឫសក្បៀស ៤ដង ក្នុងចន្លោះពេល១៥ ថ្ងៃម្តង។ | ចៃ- អណ្តើកមាសផ្កាឈូក- មេអំបៅស្លែក្តោប- ដង្កូវចោះផ្លែប៉េងប៉ោះ- ដង្កូវម្ទូរស្លឹកត្រសក់- ដង្កូវបាក់ខ្នង- ដង្កូវយោលទោង-ដង្កូវយប្ញហ្វូង | -ត្រូវបន្ថែមសារធាតុធ្វើអោយស្អិត ដើម្បីអោយទឹកថ្នាំរឹតតែល្អ។<br>-ត្រូវប្រមូលយកឫសក្បៀសដែលមានអាយុ ២ឆ្នាំកន្លះ ទៅ ៣ឆ្នាំ។ |
| ៤ | បណ្តូលពេជ្រ | Tinospora crispa | ១-ការត្រាំឫសសំណាបក្នុងទឹកថ្នាំ:<br>ដើម្បីត្រាំសំណាបសំរាប់ស្រែ ១ហត គេចិញ្ច្រាំបណ្តូលពេជ្រ ១០-១៥គក្រ រួចបុកអោយម៉ត់ដាក់ក្នុងទឹកចំនួនពី ៥០-៧៥លីត្រ ហើយកូរអោយសព្វ។<br>២-ការត្រាំវល្លិក្នុងទឹកហូរ: កាត់វល្លិខ្លីៗប្រវែង ៣តឹក ហើយចងវានៅចន្លោះស្ទឹង២ មើលទៅរាងដូចជណ្តើរ។<br>៣-ការពង្រាយកំណាត់វល្លិ : កាត់វល្លិជាកំណាត់ខ្លីប្រវែង ១ម៉ែត្រ។ កំណាត់នីមួយៗត្រូវឆ្វាយធ្វើជាចង្វាយ ហើយចងចំកណ្តាល រួចហើយដំវានឹងព្រនង់ | -ត្រាំឫសសំណាបក្នុងទឹកថ្នាំនេះក្នុងរយះពេល ១២ម៉ោង មុននឹងស្ទូង។<br>- ដាក់ជណ្តើរនេះនៅត្រង់ទ្វារទឹកហូរចូលស្រែ។<br>- ពង្រាយចង្វាយវល្លិអោយបានស្មើគ្រប់កន្លែងនៅក្នុងស្រែនៅពេលស្ទូង និងនៅពេលស្រូវចេញកួរដំបូង។ សំរាប់ផ្ទៃដី ១ហតគេកាត់ វល្លិចំនួន ៦០គក្រ ។ | ដង្កូវយោលទោង ដង្កូវរូងដើម ស្រឹងខ្មៅខ្នង មមាចត្នោត មមាចខៀវ និង សត្វល្អិតជាច្រើនប្រភេទទៀត។ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | ថ្នាំជក់ | Nicotiana tabaccum | ១- យកដើម ឬទ្រនង់ស្លឹកថ្នាំ ស្ងោរឬត្រាំទឹក ៣ ទៅ៤ថ្ងៃ។ | | សំរាប់ការពារសត្វល្អិតច្រើនប្រភេទ | |
| ៦ | ទន្ទ្រានខែត | Eupatorium odoratum | ១-ស្លឹកស្ងួត ៤ខាំ ដាក់ក្នុងទឹក ៣លីត្រ រួចដាំអោយពុះ ១០នាទី ទុកអោយត្រជាក់ទើបច្រោះ។<br>២-ស្លឹកស្ងួត ៤ខាំ ដាក់ក្នុងទឹក ៣លីត្រហើយបិតដោយយកចំហាយវា" ទឹកបិត" ជាតិថ្នាំដែលបាន ២លីត្រ ត្រូវបាញ់សុទ្ធតែម្តង។ | បាញ់ទឹកថ្នាំនេះនៅលើថ្នាលបន្លែ | ចៃ ដង្កូវកាត់ស្លឹក ដង្កូវរយ និងសត្វល្អិត នៅក្នុងឃ្លាំងសណ្តែកបាយ | ត្រូវប្រើដើមដែលមានកំពស់លើសពី ៣តឹក។ ដើមដែលតូចជាងនេះមានធាតុសកម្មតិចណាស់។ |
| ៧ | ឈូករត្ន័ | Helianthus annuus | -យកផ្កាស្ងួតកិនអោយម៉ត់ រួចលាយជាមួយដីឥដ្ឋម៉ត់ និងទឹក | ម្សៅផ្កាឈូកស្ងួត៦-៧ ស្លាបព្រា បាយសំរាប់លាយទឹក ៤លីត្រ | វាអាចកំចាត់សត្វល្អិតច្រើនប្រភេទ | |
| ៨ | ទៀបស្រុក | Anona squimosa | យកគ្រាប់ទៀបកិនអោយខ្ទេច ហើយលាយជាមួយទឹក ទើបយកទៅបាញ់ | | សត្វល្អិតចង្រៃ ស្រមោច និងដង្កូវផ្សេងៗ | |
| ៩ | ខ្ទឹមស ម្ទេស ខ្ទឹមបារាំង ម្រះ | | ១-យកខ្ទឹមស ៣-៤កំពឹស នឹងស្លឹកម្រះ ២ដៃ នឹងខ្ទឹមបារាំង២-៣ ដុំ នឹងម្ទេស២-៣ផ្លែ បុកអោយម៉ត់ ហើយយកទៅដាំអោយពុះ ទុកអោយត្រជាក់ រួចលាយទឹកថែម ៤-៥ ភាគរយ កូរអោយសព្វ។ | | កំចាត់សត្វល្អិតច្រើនប្រភេទ | មិនត្រូវទុកទឹកថ្នាំនេះអោយហួសពី ២ថ្ងៃឡើយ។ |
| ១០ | ជីអង្កាម | Cacalia precombens | ត្រូវដាំរុក្ខជាតិនេះនៅជុំវិញសួនបន្លែ ព្រោះក្លិនរបស់វាធ្វើអោយសត្វល្អិតខ្លាច រអាមិនហ៊ានមកជិត។ | | | |

- ក្រៅពីរុក្ខជាតិខាងលើនៅមានរុក្ខជាតិមួយចំនួនទៀតដែលកសិករនៅតាមតំបន់មួយចំនួនបានប្រើសំរាប់ផ្សំជាថ្នាំកំចាត់សត្វល្អិតផងដែរដូចជា ក្តួច ស្លែង ........។ល។

## ៥.២. ថ្នាំពុលកសិកម្ម និងសុវត្ថិភាពក្នុងការប្រើប្រាស់

ថ្នាំពុលកសិកម្មមានច្រើនប្រភេទ ហើយមានប្រសិទ្ធិភាពទៅតាមប្រភេទដំណាំ និងប្រភេទសត្វល្អិតចង្រៃដែលបំផ្លាញ។ ការកំចាត់ដោយប្រើថ្នាំពុលមានផលវិបាកខ្លះៗ ព្រោះវាអាចធ្វើអោយប៉ះពាល់ដល់សុខភាពមនុស្ស សត្វ បរិស្ថាន ឬអាចអោយខូចដល់ដំណាំ ប្រសិនបើគេប្រើប្រាស់ពុំសមស្របតាមលក្ខណះបច្ចេកទេស។ តែបើអ្នកប្រើស្គាល់ និងគោរពតាមការណែនាំរបស់អ្នកបច្ចេកទេសនោះការប្រើថ្នាំពុលប្រាកដជាមានប្រសិទ្ធិភាពខ្ពស់ហើយមិនបណ្តាលអោយគ្រោះថ្នាក់ដល់អ្នកបរិភោគផលិតផលឡើយ។

### ៥.២.១ និយមន័យ

ថ្នាំពុលកសិកម្មជាផលិតផលគីមីដែលអាចសំលាប់ ឬកំចាត់កត្តាចង្រៃដូចជា សត្វល្អិត កណ្តុរ ផ្សិត ស្មៅចង្រៃដែលបណ្តាលអោយខូចខាតដល់ដំណាំ និងស្បៀងរក្សាទុក។

### ៥.២.២ ក្រុមថ្នាំពុលកសិកម្ម

ថ្នាំពុលកសិកម្មត្រូវបានគេចាត់ជាក្រុម យោងទៅតាមប្រសិទ្ធិភាពក្នុងការកំចាត់កត្តាចង្រៃនីមួយៗ ដូចតទៅ:

- ក្រុមថ្នាំសត្វល្អិត ........................................... សត្វល្អិត
- ថ្នាំចៃ ...................................................... ប្រភេទចៃ
- ថ្នាំខ្យង .................................................... ប្រភេទខ្យង
- ថ្នាំណេមាតូត ............................................. ប្រភេទណេមាតូត
- ថ្នាំបាក់តេរី ................................................. ប្រភេទបាក់តេរី
- ថ្នាំផ្សិត ...................................................... ប្រភេទផ្សិត
- ថ្នាំស្មៅ ...................................................... ប្រភេទស្មៅ

### ៥.២.៣ បែបផែនសកម្មភាពរបស់ថ្នាំពុលកសិកម្ម

ថ្នាំពុលកសិកម្មអាចកំចាត់កត្តាចង្រៃដោយមានរបៀបផ្សេងៗពីគ្នា ដែលគេហៅថាបែបផែនសកម្មភាពនោះមានដូចជា:

- ពុលតាមការលេបចូល
- ពុលតាមការជ្រាបចូលតាមស្បែកពេលដែលសត្វល្អិតប៉ះត្រូវ
- ពុលតាមការដកដង្ហើម

### ៥.២.៤- ការជ្រើសរើសថ្នាំពុលកសិកម្ម

មុននិងទិញថ្នាំពុលកសិកម្មណាមួយ ជាបឋមកសិករត្រូវស្គាល់ប្រភេទកត្តាចង្រៃ និងសំរេចថាពេលណាដែលចាំបាច់ត្រូវប្រើថ្នាំ ។ ហើយបើអ្នកណាមិនបានដឹងទេ ត្រូវស្វែងរកយោបល់ណែនាំពីអ្នកជំនាញរបស់ភ្នាក់ងារកសិកម្ម ឬ កសិករដែលមានបទពិសោធន៍ ។ ពេលខ្លះការប្រើវិធីដាំដុះ ឬវិធីជីវសាស្ត្រអាចមានប្រសិទ្ធិភាពជាង។

ពេលដែលចាំបាច់ត្រូវប្រើប្រាស់ថ្នាំពុលកសិកម្ម អ្នកប្រើប្រាស់ត្រូវក្តាប់អោយបានដូចតទៅ:

- ថ្នាំដែលត្រូវប្រើ និងគ្រោះថ្នាក់របស់ថ្នាំទាំងនោះ
- ពេលវេលា និង ចំនួនដងនៃការប្រើប្រាស់
- កំរិតលាយថ្នាំ
- វិធីបង្កាគ្រោះថ្នាក់

### ៥-២-៥-គ្រោះថ្នាក់

### ក-គ្រោះថ្នាក់ពុលចល់មនុស្ស និង សត្វ

ថ្នាំពុលកសិកម្មចូលក្នុងខ្លួនមនុស្សតាមរយៈ ស្បែក មាត់ ការដកដង្ហើម

**ការប៉ះតាមស្បែក:** ការប៉ះតាមស្បែកអាចកើតមានឡើង:

- ពេលដៃ មុខ ភ្នែក គ្មានរបាំងការពារ ត្រូវប៉ះនិងទឹកថ្នាំសុទ្ធ ឬទឹកថ្នាំដែលបានលាយហើយ
- ពេលដែលសំលៀកបំពាក់សើម ឬប្រឡាក់ដោយទឹកថ្នាំ
- ពេលដែលយើងពាក់ស្រោមដៃ និង ស្បែកជើងរហែក ហើយប្រឡាក់និងថ្នាំ
- ពេលដែលអ្នកបាញ់ថ្នាំត្រូវទឹកថ្នាំជះលើខ្លួន

**ការចូលតាមមាត់**

- បណ្តាលមកពីហូបចំណី ផឹក និង ជក់បារីនៅពេលដែលកំពុងប៉ះពាល់ថ្នាំពុល

**ការចូលតាមការដកដង្ហើម**

- ការដកដង្ហើមចូលនូវធូលី និងចំហាយទឹកថ្នាំ
- ពេលបាញ់ថ្នាំក្រោមខ្យល់
- មិនបានប្រើប្រាស់ប្រដាប់ដកដង្ហើម

**ខ- ធ្វើអោយក្រខ្វក់ដល់បរិស្ថាន:** មូលហេតុជារួមនៃការធ្វើអោយកខ្វក់នោះមាន

- ការហៀរកំពប់ លេចធ្លាយនៅពេលដឹកជញ្ជូន ស្តុកទុក ពេលលាយ និងដាក់ថ្នាំ
- ការរៀបចំទុកដាក់ធុងថ្នាំ ថ្នាំសេសសល់ ឬកញ្ចប់ថ្នាំទទេនៅក្នុងស្រែ ចំការ

- ចាក់ទឹកថ្នាំដែលលាយរួច ឬទឹកលាងធុងទៅក្នុងទឹកបឹងបួរ ឬនៅលើមាត់ផ្លូវ
- លាយថ្នាំលើសកំរិត ហើយបាញ់ក្នុងពេលខ្យល់កំពុងបក់បោកខ្លាំងដែលបណ្តាលអោយទឹកថ្នាំខ្ចាតចេញទៅឆ្ងាយ។
- ការប្រើប្រាស់ថ្នាំពុលកសិកម្មនៅជិតមាត់ស្ទឹង បឹងបួរដែលប្រើប្រាស់សំរាប់ទឹកផឹក ឬនៅក្បែរស្រះសំរាប់ចិញ្ចឹមត្រី។

### ឥ. ការពុលដល់រុក្ខជាតិ

ថ្នាំពុលកសិកម្ម គេប្រើសំរាប់កំចាត់កត្តាចង្រៃដែលធ្វើអោយខូតខាតដល់ទិន្នផលដំណាំ ។ ប៉ុន្តែវាក៏អាចធ្វើអោយគ្រោះថ្នាក់ដល់ដំណាំយើងផងដែរ ដែលគេហៅថា ពុលដល់រុក្ខជាតិ។ រុក្ខជាតិដែលពុលមានសភាពស្លោកខ្លោចឡើងពណ៌លឿង មានចំនុចត្នោត ស្រពោន និងក្រិន ។ ការពុលនេះបណ្តាលមកពី :

- ការប្រើប្រាស់ថ្នាំលើសកំរិតការណែនាំដែលមានចែងនៅលើស្លាក
- ការលាយថ្នាំគីមីច្រើនមុខចូលគ្នា ដែលមិនសមស្របតាមបច្ចេកទេស
- បាញ់ថ្នាំនៅពេលថ្ងៃក្តៅខ្លាំង
- ការប្រើថ្នាំផ្សេងទៀតនៅក្បែរដំណាំដែលងាយពុលដោយសារថ្នាំទាំងនោះដូចជា ថ្នាំសំលាប់ស្មៅភាគច្រើននាំអោយពុលដល់ដំណាំ
- កាលណាថ្នាំលាយពុំបានសព្វល្អ ហើយយកទៅប្រើ ឬប្រើឧបករណ៍ដែលទឹកថ្នាំចេញជាដំណក់ធំៗ ។

➢ **កាកសំណល់ថ្នាំនៅក្នុងរុក្ខជាតិ**

ថ្នាំអាចស្ថិតស្ថេរនៅក្នុងដំណាំក្រោយពីបាញ់ថ្នាំលើដំណាំ។ ចំពោះដំណាំយកមើម គឺហាមមិនអោយបាញ់ថ្នាំក្រោយពេលដំណាំចេញផ្កា និងហាមមិនអោយបាញ់ថ្នាំលើដំណាំដែលប្រើជាអាហារស្រស់ដូចជា ខ្ទឹម ស្ពៃ ជី..។ល។ បើចាំបាច់ត្រូវបាញ់ថ្នាំអោយបានមុនការប្រមូលផលយ៉ាងតិច ២០ថ្ងៃ។

ប៉ុន្តែបន្លែ និងផ្លែឈើអាចអនុញ្ញាតិអោយហូបបាន កាលណាមានបរិមាណថ្នាំតិចជាង ០.០០៥ មីលីក្រាម នៅក្នុងផ្លែឈើ ឬ បន្លែ។

## ៥.២.៦.ការការពារ និងការប្រើប្រាស់ថ្នាំពុលអោយមានសុវត្ថិភាព

### មុនពេលបាញ់ថ្នាំ

- ទុកថ្នាំពុលអោយផុតពីដៃក្មេង និងទុកអោយឆ្ងាយពីកន្លែងទុកដាក់ម្ហូបអាហារ
- អានបទបញ្ជាលើស្លាកថ្នាំ និងអនុវត្តតាមបទបញ្ជាដោយប្រុងប្រយ័ត្ន

- អ្នកប្រើប្រាស់ថ្នាំពុលត្រូវពាក់វ៉ែនតាការពារភ្នែក ស្រោមដៃធ្វើពីកៅស៊ូ ប្រដាប់ការពារផ្លូវដកដង្ហើម ស្បែកជើងកៅស៊ូកវែង ពាក់អាវដៃវែង និងខោជើងវែង ហើយត្រូវមានសុខភាពល្អ
- មិនត្រូវប្រើដៃទៅកូរក្នុងទឹកថ្នាំទេ "ហាមប្រើដៃកកូរទឹកថ្នាំ"

**<u>ពេលបាញ់ថ្នាំ</u>**

- មិនត្រូវបរិភោគអាហារ ឬផឹកទឹក ឬជក់បារីនៅពេលកំពុងបាញ់ថ្នាំពុល
- មិនត្រូវបាញ់ថ្នាំនៅពេលថ្ងៃក្តៅខ្លាំង "បាញ់ថ្នាំនៅពេលល្ងាច មេឃស្រលះល្អគ្មានភ្លៀង"
- មិនត្រូវផ្លុំក្បាលបិចដែលស្ទះ ហើយត្រូវសំអាតក្បាលបិចដោយប្រើបំណែកឈើតូចៗ ឬដើមស្មៅ
- ត្រូវបាញ់ថ្នាំនៅពីខាងលើខ្យល់ ឬនៅពេលស្ងប់ខ្យល់
- មិនត្រូវបាញ់ថ្នាំលើសពី ២ម៉ោងក្នុងមួយថ្ងៃ
- មិនអនុញ្ញាតិអោយអ្នកមិនចេះ កុមារ និងស្ត្រីមានផ្ទៃពោះបាញ់ថ្នាំឡើយ
- បញ្ឈប់ការបាញ់ថ្នាំទាំងអស់មុនការប្រមូលផល ព្រោះគ្រប់តែថ្នាំពុលសុទ្ធតែមានរយះពេលមួយដែលត្រូវរង់ចាំអោយវារលាយអស់ជាតិពុល "អានផ្លាកសញ្ញានៅលើដប ឬកញ្ចប់"

**<u>ក្រោយពេលបាញ់ថ្នាំ</u>**

- លាងសំអាត និងត្រួតពិនិត្យឧបករណ៍បាញ់ថ្នាំនៅពេលបញ្ចប់
- មិនត្រូវចាក់ទឹកថ្នាំដែលនៅសល់ ឬទឹកលាងបំពង់បាញ់ថ្នាំក្នុងប្រភពទឹកទន្លេ អូរ ស្ទឹង បឹងបួរ ត្រពាំង ឬជិតប្រភពអណ្តូង។
- កាកសំណល់ថ្នាំពុលត្រូវដុត និងកំទេចចោល ឬកប់ក្នុងរណ្តៅជំរៅកន្លះម៉ែត្រ
- ក្រោយពីបានបញ្ចប់ការបាញ់ថ្នាំ ត្រូវដោះសំលៀកបំពាក់យកទៅបោកគក់ និងងុតលាងខ្លួនប្រាណជាមួយសាប៊ូអោយបានស្អាតជានិច្ច។

**៥.២.៧.<u>ចំណាត់ថ្នាក់ថ្នាំពុល</u>:** "សូមមើលក្នុងតារាងឧបសម្ព័ន្ធស្តីពីថ្នាំពុលការពារដំណាំ និងបញ្ហារបស់វា" ។ តាមភាពពុលរបស់ថ្នាំពុលកសិកម្ម គេចែកវាជា ៤ក្រុម:

- ក្រុម ១ក : កំរិតពុលខ្ពស់បំផុត
- ក្រុម ១ខ : កំរិតពុលខ្ពស់
- ក្រុម ២ : កំរិតពុលមធ្យម
- ក្រុម ៣ : កំរិតពុលខ្សោយ

### ៥.២.៨. រោគសញ្ញានៃការពុលថ្នាំ

- **ការពុលខ្សោយ ឬការចាប់ផ្តើមឈានទៅរកដំណាក់កាលពុលខ្លាំង:** អ្នកជំងឺមានអាការរោគដូចជា ខ្សោយ ឈឺក្បាល វិលមុខ បែកញើស ស្រវាំងភ្នែក ចេញទឹកមាត់ មិនស្រួលក្នុងទ្រូង ក្រហាយភ្នែក រមួលពោះ រាគរុះខុសធម្មតា កន្ទាក់សរសៃ ឬសាច់ដុំ..........។ល។
- **ការពុលខ្លាំង:** អ្នកជំងឺមានអាការរោគដូចជា ឈឺពោះ ជីពចរដើរលឿន ដកដង្ហើមញាប់ ក្អួតចង្អោរ មិនអាចដើរបាន ពិបាកដកដង្ហើម ញាក់ញ័រ សន្លប់ ហើយអាចមានជំងឺធ្ងន់ជាងនេះទៅទៀត។

### ៥.២.៩. ការសង្គ្រោះបន្ទាន់

ការបង្ការការពុលវាងាយស្រួលជាងការព្យាបាល ដូចនេះត្រូវប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតចង្រៃដោយប្រុងប្រយត្ន័ជាទីបំផុត។ ក្នុងការព្យាបាលអ្នកដែលពុលថ្នាំត្រូវចាត់ការអោយបានឆាប់រហ័សបំផុត។

- ត្រូវអញ្ជើញវេជ្ជបណ្ឌិត ឬដឹកអ្នកជំងឺទៅមន្ទីរពេទ្យជាបន្ទាន់
- ត្រូវបង្ហាញដល់វេជ្ជបណ្ឌិត នូវផ្លាកសញ្ញាលើសំបកថ្នាំ ហើយបញ្ជាក់ប្រាប់ពីមូលហេតុនៃការពុល

**<u>ពេលរង់ចាំជំនួយសង្គ្រោះពីវេជ្ជបណ្ឌិត យើងអាចជួយអ្នកជំងឺដូចតទៅ</u>**

- ដោះសំលៀកបំពាក់ដែលប្រលាក់ថ្នាំចេញ ហើយលាងសំអាតខ្លួនប្រាណ និងសក់ដែលប្រលាក់ថ្នាំ
- ទឹកថ្នាំ ឬម្សៅថ្នាំ ដែលខ្ទាតចូលភ្នែកអាចជ្រាបចូលបានយ៉ាងរហ័ស ត្រូវលាងសំអាតជាបន្ទាន់ដោយប្រើទឹកស្អាត ត្រូវលាងភ្នែកយ៉ាងតិចបំផុត ១០នាទី ។
- ពេលសង្ស័យមានការពុល ដាច់ខាតមិនត្រូវផឹកស្រា ឬទឹកដោះគោឡើយ
- ត្រូវទុកដាក់អ្នករងគ្រោះអោយបានស្រួល និងស្ងប់ស្ងាត់បើមានការពុលតាមមាត់ត្រូវធ្វើអោយក្អួតចេញអស់ដោយផឹកទឹកក្តៅឧណ្ហៗមួយកែវលាយនិងអំបិល ឬយកចង្អុរដែលលូកចូលក្នុងបំពង់កទាល់តែក្អួត។

### ៥.២.១០. ការថែរក្សាបរិស្ថាន

ការថែរក្សាបរិស្ថានគឺជាភារកិច្ចរបស់ពលរដ្ឋគ្រប់ៗរូប។ ដូចនេះ យើងជាអ្នកប្រើប្រាស់ថ្នាំពុលកសិកម្មគួរតែ :

- កុំប្រើថ្នាំពុលណាដែលចែងក្នុងផ្លាកថា គ្រោះថ្នាក់ដល់សត្វឃ្មុំនៅពេលដំណាំចេញផ្កា
- កុំប្រើប្រាស់ថ្នាំពុលកសិកម្មនៅជិតប្រភពទឹក និងជិតផ្ទះសំបែង បើមានការលេចធ្លាយត្រូវប្រញាប់រោយដី ឬអាចម៍រណារដើម្បីស្រូបយកទឹកថ្នាំឬ បោសសំអាតអោយជ្រះដោយប្រុងប្រយត្ន័បំផុត
- ជ្រើសរើសថ្នាំណាដែលមានប្រសិទ្ធិភាព និងមានកំរិតពុលទាប ហើយមានរយៈពេលពុលខ្លី
- ផ្តល់ដំណឹងទៅកសិករដទៃជាមុន អំពីទីកន្លែងត្រូវបាញ់ថ្នាំដោយសរសេរជាផ្លាក ឬដាក់ផ្លាកសញ្ញាក្បាលខ្មោច
- ត្រូវធានាសុវត្ថិភាពដល់សត្វមានប្រយោជន៍ដែលរួមចំណែកក្នុងការកំចាត់សត្វល្អិត និងកណ្តុរតាមលក្ខណៈធម្មជាតិ

# ការប្រើប្រាស់ថ្នាំពុលកសិកម្មអោយមានសុវត្ថិភាព




ការទិញ និងការជ្រើសរើសយកប្រភេទថ្នាំសំលាប់សត្វល្អិត




ការស្លៀកពាក់ការពារខ្លួន



ការរៀបចំធុងបាញ់ថ្នាំ



ការលាយថ្នាំពុល



មិនត្រូវអោយអ្នកមិនចេះនិងកុមារបាញ់ថ្នាំឡើយ



កុំបាញ់ថ្នាំនៅពេលឃើញមេឃជិតភ្លៀង



កុំបាញ់ថ្នាំពុលបញ្ច្រាស់ខ្យល់



ការអនុវត្តការបាញ់ថ្នាំ






ការបោះចោលនូវសំបកធុង ដប ឬកំប៉ុងទទេនៃថ្នាំសំលាប់សត្វល្អិត



លាងសំអាតខ្លួនប្រាណ និងសំលៀកបំពាក់ក្រោយពេលបាញ់ថ្នាំ

# រោគសញ្ញនៃការពុលថ្នាំសំលាប់សត្វល្អិត

## ការពុលកំរិតមធ្យម



រមួលពោះ



បែកញើសខុសធម្មតា



ការកន្ត្រាក់សាច់ដុំ

## ការពុលកំរិតធ្ងន់



ក្អួត



ពិបាកដកដង្ហើម



សន្លប់



ការពុលថ្នាំ   និងជំនួយសង្គ្រោះបឋម

## ៥.២.១១.វិធានការណ៍ការពារ និង កំចាត់កត្តាចង្រៃលើដំណាំឈើហូបផ្លែ:

### ក.Gold dust weevil :

មេចំណាស់រស់នៅជាក្រុម ហើយពួកវាស៊ីបំផ្លាញស្លឹកស្វាយ។





### វិធានការណ៍ការពារ និងកំចាត់

- ប្រសិនបើសត្វល្អិតនេះមិនសូវច្រើន អង្រួនដើមស្វាយហើយបំផ្លាញសត្វល្អិតដែលធ្លាក់នោះចោល
- ប្រើថ្នាំ Monocrotophos ឬ Methamidophos ចំនួន ២៥សេសេ លាយទឹក ២០លីត្រ ត្រូវបាញ់អោយសព្វទ្រង់ទ្រាយដើម។
- ប្រើថ្នាំ Carbayl ចំនួន ៦០ក្រាម លាយទឹក ២០លីត្រ ត្រូវបាញ់អោយសព្វទ្រង់ទ្រាយនៃដើម។

### ខ- Leaf Miner

វាតែងតែកើតឡើងក្នុងអំឡុងពេលលាស់ត្រួយនៃដំណាំក្រូច។ គេបានរកឃើញថាដង្កូវចូលចិត្តចូលទៅក្នុងស៊ីផ្នែកខាងក្រោមនៃផ្ទៃស្លឹកជាងផ្នែកខាងលើនៃផ្ទៃស្លឹក។ ស្លឹកដែលរងការខូចខាតអាចស្វិតនិងធ្លាក់ចុះមកដី។

ចំពោះដំណាំនៅតូច ការបំផ្លាញធ្ងន់ធ្ងរនាំអោយវាគ្មានសុខភាព និងលូតលាស់មិនសូវល្អ។





### វិធានការណ៍ការពារ និងកំចាត់

- សំអាតស្មៅ និងព្រៃនៅជុំវិញចំការដែលជាជំរករបស់សត្វល្អិតចង្រៃ
- ត្រូវប្រមូលស្លឹកដែលមានជំងឺ និងកាត់មែកតូចៗណាដែលស្លឹករងការបំផ្លាញខ្លាំងដុតចោល
- ប្រើថ្នាំ Flufenoxuron (Cascade 5EC) ចំនួន ៦សេសេ លាយទឹក ២០លីត្រ។
- ប្រើថ្នាំ Cyfluthrin ចំនួន ៦សេសេ លាយទឹក ២០លីត្រ ។

## គ- **Fruit Borer**: (ដង្កូវចោះផ្លែ)

ផ្លែដែលរងការបំផ្លាញគឺមានការប្រលាក់ដោយអាចម៍ដង្កូវ ផ្លែរលួយឬ ស្អុយ ហើយក្រោយមកធ្លាក់ចុះមកដី។ ដង្កូវចាប់ផ្តើមបំផ្លាញនៅពេលដែលផ្លែវានៅតូចមានអាយុលើសពី១ខែកន្លះ ហើយបន្តរហូតដល់ពេលប្រមូលផល។ វាអាចខូចខាតទាំងស្រុង ប្រសិនបើសត្វល្អិតមានការបំផ្លាញយ៉ាងខ្លាំងក្លា។



### វិធានការណ៍ការពារ និងកំចាត់

- ត្រូវរុំផ្លែក្រូចដើម្បីការពារការបំផ្លាញពីដង្កូវចោះផ្លែ
- ប្រមូលផ្លែដែលខូចកប់ ឬដុតចោល
- ប្រើថ្នាំ Methamidophos ចំនួន៣០សេសេ លាយទឹក ២០លីត្រ ត្រូវបាញ់អោយសព្វទ្រង់ទ្រាយនៃដើម។

## ឃ- **Leaf Eating caterpillar**: (ដង្កូវស៊ីស្លឹក)

ក្រោយពីកូនដង្កូវបានចាប់ផ្តើមញាស់ វាក៏ចាប់ផ្តើមស៊ីបំផ្លាញត្រួយ និងស្លឹកខ្ចីៗដោយសន្សឹមៗ។ នៅពេលដែលវាមានអាយុប្រហែល ៥-៦ថ្ងៃ ដង្កូវនិងបំផ្លាញយ៉ាងលឿន ហើយអាចបណ្តាលអោយកូនឈើហូបផ្លែដែលនៅតូចងាប់បាន។

### វិធានការណ៍ការពារ និងកំចាត់

- បេះយកពង និងដង្កូវចេញ ហើយបំផ្លាញវាចោល
- ប្រើថ្នាំ Methamidophos ចំនួន៣០សេសេ លាយទឹក ២០លីត្រ ត្រូវបាញ់អោយសព្វទ្រង់ទ្រាយនៃដើម។



## ២-Mango Leafhopper: (មមាច)

វាជញ្ជក់យករុក្ខរសពីត្រួយស្វាយដែលទើបតែលាស់ថ្មី ហើយបណ្តាលអោយស្លឹកដែលលាស់ថ្មីនោះឡើងរមួលចុះ ធ្វើអោយខុសពីភាពដើម និងខ្ចីជាងមុន។ តែមស្លឹកក្លាយទៅជាស្ងួត។ នៅដំណាក់កាលចេញផ្កា ផ្កាដែលរងការបំផ្លាញនិងត្រូវខ្ចីជាងមុន ហើយធ្លាក់ចុះមកដី។



### វិធានការណ៍ការពារ និងកំចាត់

- ត្រូវពិនិត្យមើលសត្វល្អិតនៅលើកន្លែងដែលទើបមានការលូតលាស់ថ្មីទាំងផ្នែកខាងលើ និងខាងក្រោមនៃស្លឹក
- ប្រើថ្នាំក្រុម **Pyrethroid** :

- Deltamethrin (Decis 2.5EC) ចំនួន ១០សេសេ លាយទឹក ២០លីត្រ។
- Fenvalerate ( Sumicidin 20 EC) ចំនួន ១០សេសេ លាយទឹក ២០លីត្រ។
- Cypermethrin (Cyperin 10EC) ចំនួន ១០សេសេ លាយទឹក ២០លីត្រ។
- Lambda-cyhalothrin (Karate 2.5EC) ចំនួន ៨សេសេ លាយទឹក ២០លីត្រ។
- Permethrin (Ambush 10EC) ចំនួន ១០សេសេ លាយទឹក ២០លីត្រ។
- Cyfluthrin (Baythroid 5EC) ចំនួន ៤សេសេ លាយទឹក ២០លីត្រ

### ច- Thrip : (មម៉ង់)

កូន និងមេចំណាស់ជញ្ជក់យករុក្ខរសពីស្លឹកដែលទើបលាស់ថ្មី ហើយស្លឹកនោះក្លាយជារេញៗដោយខ្លោចតែមស្លឹក និងធ្លាក់ចុះមកដី។ រីឯមែកដែលទើបតែចេញពន្លក បើរងការបំផ្លាញពីវា ពន្លកនោះមិនអាចចេញស្លឹកបានទេ ហើយក្លាយទៅជាក្រៀមស្វិត។ នៅដំណាក់កាលចេញផ្កាគេតែងតែឃើញវាភាគច្រើននៅក្នុងផ្កា កន្លែងដែលវារស់នៅបានធ្វើអោយខូចខាត និង បណ្តាលអោយផ្កាធ្លាក់ចុះមក។ ចំពោះផ្លែវិញរោគសញ្ញានៃការខូចខាតគឺមានស្នួតពណ៌ប្រផេះពេញទាំងផ្លែ។ ផ្លែដែលខូចខាតធ្ងន់ធ្ងរគ្មានទីផ្សារឡើយ។





### វិធានការណ៍ការពារ និងកំចាត់

- ត្រូវត្រួតពិនិត្យសត្វល្អិតនេះដោយប្រុងប្រយត្ន័នៅក្នុដំណាក់កាលលាស់ត្រួយ និងចេញផ្លែ
- ប្រើថ្នាំ Lambda-cyhalothrin (Karate 2.5EC) ចំនួន ៨សេសេ លាយទឹក ២០លីត្រ។
- ប្រើថ្នាំ Carbaryl (85WP) ចំនួន ៦០ក្រាម លាយទឹក ២០លីត្រ។
- ប្រើថ្នាំ Monocrotophos (60SCW) ចំនួន ២៥សេសេ លាយទឹក ២០លីត្រ

## ឥ-Red Mite: (ពីងពាងក្រហម)

វាជាសត្វល្អិតដែលអាចបំផ្លាញដំណាំច្រើនមុខណាស់។ មេចំណាស់ ហើយនិងកូនរបស់វាជញ្ជក់យករុក្ខរសពី ស្លឹកដំណាំ។ ស្លឹកប្រែពណ៌ពីបៃតងខ្ចី និងធ្លាក់ចុះមកដី។ នៅក្នុងដំណាក់កាលចេញផ្លែវាជញ្ជក់យករុក្ខរសពីផ្លែផងដែរ វាធ្វើអោយផ្លែមានពណ៌បៃតងព្រលែត។ ប្រសិនបើការបំផ្លាញរបស់វាមានសភាពធ្ងន់ធ្ងរ ផ្លែនៅតូចអាចធ្លាក់ចុះមកដី។



### វិធានការណ៍ការពារ និងកំចាត់

- គេអាចការពារកុំអោយមានវត្តមានពីងពាងក្រហមនេះនៅរដូវបន្ទាប់ទៀត ដោយភ្ជួរដីចំការអោយបានជ្រៅនៅក្រោយពេលប្រមូលផលដំណាំ ព្រោះថាវាចូលចិត្តជ្រកនៅក្រោមស្លឹកឈើងាប់ ឬ កាកសំណល់នៅពេលប្រមូលផល។
- ប្រើថ្នាំ Propagite (Omite 30WP) ចំនួន ៣០ក្រាម លាយទឹក ២០លីត្រ។
- ប្រើថ្នាំ Dicofol (Kelthane 18.5EC) ចំនួន ២០សេសេ លាយទឹក ២០លីត្រ។
- ប្រើថ្នាំ Hexythiazox (Nissorun10EC) ចំនួន ១០សេសេ លាយទឹក ២០លីត្រ។
- ប្រើថ្នាំ Dimethoate ចំនួន ៣០សេសេ លាយទឹក ២០លីត្រ។

## ឦ-Mealy Bug:

វាច្រើនប្រមូលផ្តុំគ្នារុំជញ្ជក់យកជ័រពីពន្លកមែក និងពន្លកស្លឹក។ ដំណាំដែលទទួលការបំផ្លាញពីពពួកសត្វល្អិតនេះលូតលាស់មិនបានល្អជាប្រក្រតីទេ។ ចំពោះពន្លកមែក និងពន្លកស្លឹកវិញនិងខូច។ រុក្ខជាតិទាំងមូលនិងងាប់ ប្រសិនបើការបំផ្លាញមានសភាពធ្ងន់ធ្ងរ។



### វិធានការណ៍ការពារ និងកំចាត់

- កាត់មែក និងផ្លែណាដែលមានជំងឺ រួចវាដុតចោល
- ប្រើថ្នាំ Malathion(25EC) ចំនួន ២០សេសេ លាយទឹក ១០លីត្រ
- ប្រើថ្នាំ Carbaryl (85WP) ចំនួន ៦០ក្រាម លាយទឹក ២០លីត្រ។

## ឈ-Sooty Mold: (ជំងឺផ្សិតខ្មៅ)

យើងអាចឃើញផ្សិតនៅលើស្លឹក ផ្លែ និងមែកដោយដុះនៅលើអាចម៍ចៃ...។ល។ ស្ពរ៍របស់ផ្សិតនេះអាចរាលដាលទៅដើមផ្សេងទៀតតាម ខ្យល់ និងទឹក ។



### វិធានការណ៍ការពារ និងកំចាត់

- កាត់ស្លឹក មែក និងផ្លែចេញដែលឃើញថាមានជំងឺផ្សិត ហើយដុតវាចោលកុំអោយរាតត្បាត
- ប្រើថ្នាំ CarbendaZim (50WP) ចំនួន ៦-១២ក្រាម លាយទឹក ២០លីត្រ។
- ប្រើថ្នាំ Mancozeb(80WP) ចំនួន ៤៨ក្រាម លាយទឹក ២០លីត្រ។

## ៣-Foot and Root Rot: (ជំងឺរលួយឫស និងរលួយគល់)

រោគសញ្ញាភាគច្រើននៃជំងឺនេះកើតឡើងនៅលើឫស និងសំបកនៃដើមក្រូច។ ឫសមានសារៈសំខាន់ណាស់ ព្រោះវាមានមុខងារសំរាប់ស្រូបយកទឹក និងជីជាតិ។ កាលណាឫសរលួយ វាប្តូរពណ៌ពីពណ៌ត្នោតខ្ចីទៅពណ៌ត្នោតចាស់ ហើយសំបកនៃឫសក៏របកចេញ។ ការរលួយឫសដ៏ធ្ងន់ធ្ងរអាចធ្វើអោយដើមក្រូចស្លឹកពណ៌លឿង ស្វិត ហើយមែកស្វិតងាប់។ ដើមក្រូចដែលទទួលការរាតត្បាតពីជំងឺនេះនិងងាប់ជាយថាហេតុ។





### វិធានការណ៍ការពារ និងកំចាត់

- កែលំអរដីដោយប្រើជីធម្មជាតិ ដើម្បីធ្វើអោយខ្យល់ និងទឹកជ្រាបចូលបានស្រួល
- កាត់មែកខ្លះដើម្បីអោយមានពន្លឺថ្ងៃចូលដល់គល់ក្រូច
- ចៀសវាងសកម្មភាពណាដែលអាចធ្វើអោយខូចដល់សំបកនៃឫស
- ដើមណាដែលរងការបំផ្លាញធ្ងន់ធ្ងរគួរតែគាស់វាចេញ ហើយដុតចោល
- ក្នុងករណីដែលមានការរលួយ កាត់ផ្នែកដែលខូចចេញ ហើយព្យាបាលឫសដែលនៅសល់ជាមួយថ្នាំ Metalaxyl (5G) ចំនួន ២០០ក្រាម រោយជុំវិញបរិវេណគល់ រួចស្រោចទឹកអោយសើមល្មមជុំវិញបរិវេណគល់ដែលកើតជំងឺ។ ចំពោះរលួយគល់វិញ ឆ្កិះសំបកកន្លែងដែលកើតជំងឺ ជូតអោយស្អាត រួចលាបថ្នាំ Metalaxyl (25WP) ចំនួន ៥០-៦០ក្រាម លាយទឹក ១លីត្រ។

# សរុបសៀវភៅដែលបានដកស្រង់


- សៀវភៅស្តីពី ការរៀបចំធ្វើជីកំប៉ុស្ត បោះពុម្ពជាភាសាខ្មែរ ជាជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី តាមរយៈអង្គការ IRRI និង រដ្ឋាភិបាលកម្ពុជា ឆ្នាំ១៩៩១
- សៀវភៅថ្នាំពុលការពារដំណាំ និងបញ្ហារបស់វា ដែលបានរៀបចំឡើងដោយមជ្ឈមណ្ឌលសិក្សា និង អភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)
- សៀវភៅស្តីពី បច្ចេកទេសកសិកម្មសមស្របរបស់ Padek ឆ្នាំ១៩៩១
- សៀវភៅស្តីពី បច្ចេកទេសដាំឈើសំរាប់កសិករ ឧបត្ថម្ភការរៀបចំ និង បោះពុម្ពដោយ CTSP-DANIDA , GTZ-CGFP , JICA , Cambodia-EU PRASAC និង នាយកដ្ឋានរុក្ខា-ប្រមាញ់ ឆ្នាំ ២០០៣
- សៀវភៅស្តីពី ការពង្រីកពូជស្វាយ បានបកប្រែសំរួលពី Kiatikaset Khanchanpisoot. 1989. Mango Tree Propagation Manaul. Bangkok, Thailand, ដោយមន្ទីរកសិកម្មខេត្តបាត់ដំបង និង គណកម្មការអភិវឌ្ឍន៍ដំណាំឈើហូបផ្លែខេត្តតំបន់ពាយ័ព្យប្រទេសកម្ពុជា ឆ្នាំ១៩៩៧
- Wightman, Kevyn. 1999. Good Tree Nursery Practices, International Centre for Research in Agroforestry, Nairobi, Kenya.
- FAO. 1997. Handbook for Agro-retailers in Thailand: Fertilizer and Related Inputs Recommendations for rice, field crops, vegetables, fruit trees and other crops. Technical Co-operation Program. Bangkok.
- Bangkok, Thailand 1984, Safe handling and application of agro-pesticides
- Durian Integrated Pest Management Manual 1996, Thai-German IPM in selected fruit trees, Department of Agriculture and Department of Agricultural Extension.
- Pummelo Integrated Pest Management Manual, Thai-German IPM in selected fruit trees, Department of Agriculture and Department of Agricultural Extension
- Tangerine Integrated Pest Management Manual 1996, Thai-German IPM in selected fruit trees, Department of Agriculture and Department of Agricultural Extension
- Thailand, Mango Farm Care and Management Handbook, Thai-German IPM in selected fruit trees project, Department of Agriculture and Department of Agricultural Extension
- BHUTHAN Ministry of Agriculture, Forestry Services Division (1995) Tree Nurseries Establishment and Management.